**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា**

លេខ.......✓..........គ.ជ.អ.ក

# កម្មវិធី

## មហាសន្និបាតបញ្ចប់អាណត្តិទី៨ ឆ្នាំ២០២២-២០២៦ និងបន្តអាណត្តិទី៩ ឆ្នាំ២០២៦-២០៣០

ថ្ងៃព្រហស្បតិ៍ ទី១៩ ខែមីនា ឆ្នាំ២០២៦ សាលប្រជុំធំ ទីស្នាក់ការគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា(ជាន់ទី១)

| | |
|---|---|
| ▪ ម៉ោង ១៣:៣០នាទី | : - ជួបជុំសមាជិក សមាជិកា អង្គមហាសន្និបាត<br>- គណៈកម្មាធិការប្រតិបត្តិ និងថ្នាក់ដឹកនាំ អញ្ជើញដល់ |
| ▪ ម៉ោង ១៤:០០នាទី | : - **ចាប់ផ្តើមកម្មវិធី**<br>- គោរពទង់ជាតិ នៃព្រះរាជាណាចក្រកម្ពុជា និងគោរពវិញ្ញាណក្ខន្ធ ចំពោះវីរជនដែលមានគុណបំណាច់ដល់ចលនាអូឡាំពិកកម្ពុជា និងវីរកងទ័ពដែលបានពលីក្នុងបុព្វហេតុការពារជាតិ<br>- ទស្សនាកម្រង Video ស្តីពីសមិទ្ធផលការងារអាណត្តិទី៨ ប្រចាំឆ្នាំ២០២២-២០២៦<br>- សុន្ទរកថាស្វាគមន៍ **ឯកឧត្តមបណ្ឌិត ទេសរដ្ឋមន្ត្រី ថោង ខុន ប្រធានគណៈ-កម្មាធិការជាតិអូឡាំពិកកម្ពុជា**<br>- សុន្ទរកថាបើកមហាសន្និបាត របស់ **ឯកឧត្តមបណ្ឌិតសភាចារ្យ ហង់ជួន ណារ៉ុន ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា**<br>- **ឯកឧត្តមបណ្ឌិតសភាចារ្យ ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា** អញ្ជើញនិវត្តន៍ |
| | - សម្រាកអាហារសម្រន់ (១០នាទី) |
| | - របាយការណ៍ពិស្តារអាណត្តិទី៨ ឆ្នាំ២០២២-២០២៦ និងទិសដៅអាណត្តិទី៩ ឆ្នាំ២០២៦-២០៣០ ដោយ **ឯកឧត្តម អគ្គលេខាធិការ**<br>- របាយការណ៍គណៈកម្មការហិរញ្ញវត្ថុ ដោយ ឯកឧត្តមអគ្គហេរញ្ញិក **លី កុសល** (៧នាទី)<br>- របាយការណ៍គណៈកម្មការសមភាពស្ត្រី “Women Equity” ដោយ លោកជំទាវបណ្ឌិត ប្រធាន **កុយ ពិសី** (៧នាទី)<br>- របាយការណ៍គណៈកម្មការវេជ្ជសាស្ត្រ និងវិទ្យាសាស្ត្រកីឡា ដោយ ឯកឧត្តមវេជ្ជបណ្ឌិត ប្រធាន **សុក សារឿន** (៧នាទី)<br>- របាយការណ៍គណៈកម្មការអត្តពលិក **លោក ហែម គិរី អនុប្រធាន** (៧នាទី)<br>- បោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិ អាណត្តិថ្មី អាណត្តិទី៩ ប្រចាំឆ្នាំ២០២៦-២០៣០ |
| | - សម្រាកអាហារសម្រន់ (១០នាទី) |
| | - **ឯកឧត្តមបណ្ឌិត ទេសរដ្ឋមន្ត្រី ប្រធាន** ដឹកនាំមហាសន្និបាតបន្ត<br>- ប្រកាសសមាសភាពថ្នាក់ដឹកនាំគណៈកម្មាធិការប្រតិបត្តិអាណត្តិទី៩<br>- បទបង្ហាញផែនការយុទ្ធសាស្ត្រអាណត្តិថ្មី ២០២៦-២០៣០ ដោយ ឯកឧត្តម **វ៉ាត់ ចំរើន**<br>- សុន្ទរកថាបិទមហាសន្និបាត ដោយ **ឯកឧត្តមបណ្ឌិត ទេសរដ្ឋមន្ត្រី ប្រធានមហាសន្និបាត**<br>- គោរពទង់ជាតិបិទមហាសន្និបាត និងថតរូបអនុស្សាវរីយ៍<br>- **ចប់កម្មវិធី និងអញ្ជើញពិសាអាហារសាមគ្គីអូឡាំពិក** |

*កម្មវិធីនេះមានការប្រែប្រួលក្នុងករណីចាំបាច់!*

អាសយដ្ឋាន: ផ្ទះលេខ ១ មហាវិថីសាធារណរដ្ឋប្រជាមានិតប៉ុឡូញ, សង្កាត់វាលវង់, ខណ្ឌ ៧ មករា, រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ១០១
Email: camnoc@online.com.kh Website: www.camnoc.org Facebook Page : National Olympic Committee of Cambodia

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា

# របាយការណ៍ពិស្តារ

## មហាសន្និបាតបញ្ចប់អាណត្តិទី៨ និងបន្តអាណត្តិទី៩ ឆ្នាំ២០២៦-២០៣០ របស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា

“កីឡារស់ក្នុងសន្តិភាព”

# មាតិកា


**បូកសរុបសមិទ្ធផលការងារ ឆ្នាំ២០២២-២០២៣-២០២៤-២០២៥ និងលើកទិសដៅ ឆ្នាំ២០២៦-២០៣០** ..... 3

I. **សេចក្តីផ្តើម**: ..... 3

II. **សមិទ្ធផលដ៏ធំធេងនៃមហាកីឡា SEA Games លើកទី៣២ និង ASEAN Para Games លើកទី១២ ឆ្នាំ២០២៣** ..... 3

**ក.** ស្ថានភាពទូទៅ និងលទ្ធផលបច្ចេកទេស ..... 3

**ខ.** ឆន្ទៈនយោបាយ “Political Will” ..... 5

**គ.** សូចនាករផែនការមេ និងផែនការយុទ្ធសាស្ត្រសម្រេចបានជោគជ័យលើសពីការរំពឹងទុក ..... 6

**ឃ.** សេចក្តីសន្និដ្ឋានព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ ..... 8

III. **សមិទ្ធផលការងារសំខាន់ៗ ប្រចាំអាណត្តិទី៨ ឆ្នាំ២០២២-២០២៦** ..... 9

- **ឆ្នាំ២០២២**: ..... 9
- **ឆ្នាំ២០២៣**: ..... 10
- **ឆ្នាំ២០២៤**: ..... 10
- **ឆ្នាំ២០២៥**: ..... 10

IV. **បញ្ហាប្រឈម** ..... 11

V. **ដំណោះស្រាយ** ..... 12

VI. **សេចក្តីសន្និដ្ឋាន** ..... 12

VII. **ចំពោះទិសដៅបន្តសម្រាប់អាណត្តិទី៩ ប្រចាំឆ្នាំ២០២៦-២០៣០ មានក្នុងឯកសារឧបសម្ព័ន្ធ ស្តីពីផែនការយុទ្ធសាស្ត្របន្តអាណត្តិទី៩ ។** ..... 12

# បូកសរុបសមិទ្ធផលការងារ ឆ្នាំ២០២២-២០២៣-២០២៤-២០២៥ និង លើកទិសដៅ ឆ្នាំ២០២៦-២០៣០

## I. **សេចក្តីផ្តើម**:

គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា គឺជាអង្គការកីឡាជាតិ តំណាងឱ្យចលនាអូឡាំពិកអន្តរជាតិ ជាអង្គការកីឡា មិនស្វែងរកកម្រៃ មានស្វ័យភាព និងឯករាជ្យភាពក្នុងការគ្រប់គ្រងដឹកនាំ និងអភិវឌ្ឍចលនាកីឡាអូឡាំពិក ក្នុងព្រះរាជាណាចក្រកម្ពុជា។

ដោយសារការយកចិត្តទុកដាក់ខ្ពស់ ឧបត្ថម្ភគាំទ្រ និងលើកទឹកចិត្តផ្ទាល់ពី **សម្តេចតេជោ អតីតនាយករដ្ឋមន្ត្រី** និងបន្តជំរុញការគាំទ្ររបស់ **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** បានធ្វើឱ្យចលនាអូឡាំពិកកម្ពុជាទទួលបានជោគជ័យលើការបំពេញបេសកម្មរបស់ខ្លួន គួរជាទីមោទនភាពកីឡាជាតិដ៏ឧត្តុង្គឧត្តម។ ផ្អែកលើយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល ក្រោមការដឹកនាំប្រកបដោយថាមពល និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ប្តេជ្ញាគោរព និងអនុវត្តតាមចក្ខុវិស័យគោលនយោបាយរបស់រាជរដ្ឋាភិបាលយ៉ាងខ្ជាប់ខ្ជួនបំផុត ដើម្បីជំរុញនាវាកម្ពុជាឆ្ពោះទៅកំណើនសេដ្ឋកិច្ចមធ្យមកម្រិតខ្ពស់ឆ្នាំ២០៣០ និងកម្រិតខ្ពស់ឆ្នាំ២០៥០។

គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ជាដៃគូអភិវឌ្ឍវិស័យកីឡាជាតិ ដោយសហការយ៉ាងជិតស្និតជាមួយ ក្រសួងអប់រំ យុវជន និងកីឡា សហព័ន្ធកីឡាជាតិ អង្គភាពកីឡា ក្រសួង-ស្ថាប័ន និងដៃគូឧបត្ថម្ភគាំទ្រពីវិស័យឯកជន។

គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ប្រតិបត្តិការងារតាមលក្ខន្តិកៈ បទបញ្ជាផ្ទៃក្នុងរបស់ខ្លួន និងគោរពតាម ធម្មនុញ្ញអូឡាំពិក ព្រមទាំងគោរពតាមគោលនយោបាយកីឡាជាតិ របស់រាជរដ្ឋាភិបាល។

ចលនាអូឡាំពិកកម្ពុជាពិតជាមានមោទនភាពចំពោះសមិទ្ធផល និងជោគជ័យជារៀងរាល់ឆ្នាំ និងក្នុងអាណត្តិទី៨ ដែលសម្រេចបានលទ្ធផលគួរជាទីគាប់ចិត្ត តាមផែនការយុទ្ធសាស្ត្រដែលបានកំណត់។

ក្រោយពីមហាសន្និបាតបញ្ចប់អាណត្តិទី៧ រៀបចំបោះឆ្នោតជ្រើសរើសគណៈកម្មាធិការប្រតិបត្តិថ្មីអាណត្តិទី៨ ប្រចាំឆ្នាំ២០២២-២០២៦ ត្រូវបានបញ្ចប់ដោយជោគជ័យ នាថ្ងៃទី៣០ ខែធ្នូ ឆ្នាំ២០២២ បានបើកផ្លូវការឱ្យគណៈកម្មាធិការជាតិ អូឡាំពិកកម្ពុជា មានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការចូលរួមត្រៀម និងរៀបចំព្រឹត្តិការណ៍ប្រកួតកីឡា SEA Games លើកទី៣២ និង ASEAN Para Games លើកទី១២ ឆ្នាំ២០២៣ ដោយទទួលបានជោគជ័យដ៏ត្រចះត្រចង់ជូនជាតិ និងចលនាអូឡាំពិក។

## II. **សមិទ្ធផលដ៏ធំធេងនៃមរតក** SEA Games **លើកទី៣២ និង** ASEAN Para Games **លើកទី១២ ឆ្នាំ២០២៣**

### **ក.** ស្ថានភាពទូទៅ និងលទ្ធផលបច្ចេកទេស

រាជរដ្ឋាភិបាល បានអនុញ្ញាតជាគោលការណ៍ជូនគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ទទួលធ្វើម្ចាស់ផ្ទះរៀបចំការប្រកួតកីឡា **SEA Games** ឆ្នាំ២០២៣ តាមរយៈលិខិតលេខ ៣៨៤ សជណ ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៣ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ហើយតាមលិខិតចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០១៥ របស់ក្រុមប្រឹក្សាសហព័ន្ធកីឡា អាស៊ីអាគ្នេយ៍ **"SEAGF Council"** បានចាត់តាំង គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា រៀបចំការប្រកួតកីឡា **SEA Games** លើកទី៣២ ឆ្នាំ២០២៣។

❖ SEA Games លើកទី៣២ ឆ្នាំ២០២៣

- កាលបរិច្ឆេទ : ថ្ងៃទី៥ ខែឧសភា ដល់ថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣
- ប្រទេសចូលរួម : ១១ប្រទេស នៃគណៈកម្មាធិការជាតិអូឡាំពិកតំបន់អាស៊ីអាគ្នេយ៍
- ប្រតិភូកីឡាចូលរួម : សរុបចំនួន ១២,៤០៤ នាក់
- ពិធីបើក-បិទផ្លូវការ : ពិធីបើកថ្ងៃទី៥ ខែឧសភា និងពិធីបិទថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០២៣
- ការប្រកួត **SEA Games** មាន ៣៧ប្រភេទកីឡា ៥៨១វិញ្ញាសា និងមានកីឡាក្រៅផ្លូវការ **"Demo-Sport"** ចំនួនមួយ គឺ **"Teqball"**
- តារាងលទ្ធផលមេដាយផ្លូវការ ៖

| ចំណាត់ថ្នាក់ | ប្រទេស |  |  |  |  |
|---|---|---|---|---|---|
| ១ | សាធារណរដ្ឋសង្គមនិយមវៀតណាម | ១៣៦ | ១០៥ | ១១៤ | ៣៥៥ |
| ២ | ព្រះរាជាណាចក្រថៃ | ១០៨ | ៩៦ | ១០៨ | ៣១២ |
| ៣ | សាធារណរដ្ឋឥណ្ឌូនេស៊ី | ៨៧ | ៨០ | ១០៩ | ២៧៦ |
| ៤ | ព្រះរាជាណាចក្រកម្ពុជា | ៨១ | ៧៤ | ១២៧ | ២៨២ |
| ៥ | សាធារណរដ្ឋហ្វីលីពីន | ៥៨ | ៨៦ | ១១៦ | ២៦០ |
| ៦ | សាធារណរដ្ឋសិង្ហបុរី | ៥១ | ៤២ | ៦៤ | ១៥៧ |
| ៧ | ព្រះរាជាណាចក្រម៉ាឡេស៊ី | ៣៤ | ៤៥ | ៩៧ | ១៧៦ |
| ៨ | សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា | ២១ | ២៥ | ៦៨ | ១១៤ |
| ៩ | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | ៦ | ២២ | ៦០ | ៨៨ |
| ១០ | ប្រទេសប្រ៊ុយណេដារុយសាឡឹម | ២ | ១ | ៦ | ៩ |
| ១១ | សាធារណរដ្ឋទីម័រលេស្តេ | ០ | ០ | ៨ | ៨ |

- កម្ពុជាស្ថិតនៅចំណាត់ថ្នាក់ទី៤ ក្នុងចំណោម ១១ប្រទេសជាសមាជិកចូលរួម ។

❖ ASEAN Para Games លើកទី១២ ឆ្នាំ២០២៣:

- កីឡាជនពិការអាស៊ាន កើតឡើងតាមគំនិតផ្តួចផ្តើមរបស់ លោក **Zainal Abu Zarin** ដែលជាស្ថាបនិកបង្កើតព្រឹត្តិការណ៍ប្រកួតកីឡាជនពិការអាស៊ានលើកទី១ ឆ្នាំ២០០១ នៅទីក្រុងកូឡាឡាំពួរ ប្រទេសម៉ាឡេស៊ី។
- ព្រឹត្តិការណ៍ប្រកួតកីឡាជនពិការអាស៊ាន ប្រព្រឹត្តឡើងរៀងរាល់២ឆ្នាំម្តង ស្ថិតក្រោមបទប្បញ្ញត្តិ ឬ សៀវភៅច្បាប់ "Handbook" របស់សហព័ន្ធកីឡាជនពិការអាស៊ាន (ASEAN Para Sport Federation-APSF) ក្រោមឆ័ត្ររបស់គណៈកម្មាធិការប៉ារ៉ាឡាំពិកអន្តរជាតិ "IPC" និងគណៈកម្មាធិការ ប៉ារ៉ាឡាំពិកអាស៊ី "APC" ដែលជាប្រពៃណី ព្រឹត្តិការណ៍ប្រកួតកីឡា ASEAN Para Games រៀបចំឡើងក្នុងប្រទេសដែលធ្វើម្ចាស់ផ្ទះរៀបចំការប្រកួតកីឡាអាស៊ីអាគ្នេយ៍ "SEA Games"។
- កីឡាករ កីឡាការិនី មានពិការភាពចូលរួមប្រកួតក្នុងលក្ខណៈពិការភាព ដូចជា ពិការសន្លាក់ និង សាច់ដុំតឹង ឬរឹង, ពិការចលករខួរក្បាល, ពិការដោយចលនា, ពិការចក្ខុ, ពិការអវយវៈ និងខ្សោយបញ្ញា។

- កាលបរិច្ឆេទ : ថ្ងៃទី៣ ខែមិថុនា ដល់ថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣
- ប្រទេសចូលរួម : ១១ប្រទេស នៃគណៈកម្មាធិការជាតិប៉ារ៉ាឡាំពិកអាស៊ាន និងប្រទេសទីម័រលេស្តេ
- ប្រតិភូកីឡាចូលរួម : សរុបចំនួន ២,១៤៣ នាក់
- ពិធីបើក-បិទផ្លូវការ : ពិធីបើកថ្ងៃទី៣ ខែមិថុនា និងពិធីបិទថ្ងៃទី៩ ខែមិថុនា ឆ្នាំ២០២៣
- ការប្រកួត **ASEAN Para Games** មានកីឡាចំនួន ១៣ប្រភេទ ៤៣១វិញ្ញាសា និងមានកីឡាក្រៅផ្លូវការមួយប្រភេទ គឺ **"Para E-Sports"**
- តារាងលទ្ធផលមេដាយផ្លូវការ :

| ចំណាត់ថ្នាក់ | ប្រទេស | | | | |
|---|---|---|---|---|---|
| ១ | សាធារណរដ្ឋឥណ្ឌូនេស៊ី | ១៥៨ | ១៤៨ | ៩៥ | ៤០១ |
| ២ | ព្រះរាជាណាចក្រថៃ | ១២៦ | ១០៩ | ៩៤ | ៣២៩ |
| ៣ | សាធារណរដ្ឋសង្គមនិយមវៀតណាម | ៦៦ | ៥៩ | ៧៨ | ២០៣ |
| ៤ | ព្រះរាជាណាចក្រម៉ាឡេស៊ី | ៥០ | ៣៨ | ៣៤ | ១២២ |
| ៥ | សាធារណរដ្ឋហ្វីលីពីន | ៣៤ | ៣៣ | ៥០ | ១១៧ |
| ៦ | សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា | ១៥ | ២២ | ១៨ | ៥៥ |
| ៧ | សាធារណរដ្ឋសិង្ហបុរី | ១២ | ១៥ | ១៧ | ៤៤ |
| ៨ | ព្រះរាជាណាចក្រកម្ពុជា | ៩ | ១៩ | ៤៥ | ៧៣ |
| ៩ | ប្រទេសប្រ៊ុយណេដារ៉ុយសាឡឹម | ៣ | ៣ | ២ | ៨ |
| ១០ | សាធារណរដ្ឋទីម័រលេស្តេ | ២ | ០ | ៥ | ៧ |
| ១១ | សាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ | ០ | ២ | ១០ | ១២ |

- កម្ពុជាស្ថិតនៅចំណាត់ថ្នាក់ទី៨ ក្នុងចំណោម ១១ប្រទេសជាសមាជិកចូលរួម ។

**ខ.** ឆន្ទៈនយោបាយ **"Political Will"**

ក្នុងនាមជាម្ចាស់ផ្ទះ កម្ពុជាបានផ្ដល់នូវទស្សនាទានថ្មីសម្រាប់ចលនាកីឡាអូឡាំពិកអន្តរជាតិ-ចលនាប៉ារ៉ាឡាំពិកអន្តរជាតិ និងផ្លាស់ប្ដូរផ្នត់គំនិតអូឡាំពិក-ប៉ារ៉ាឡាំពិកនិយមចាស់ បង្កើតរូបមន្តថ្មីបែបផែនកម្ពុជា "**ប្រទេសតូច មានបេះដូងធំទូលាយ**" និង "**សន្សំសំចៃតែបង្កើតនាពអស្ចារ្យ**" ក្រោមសសរស្តម្ភយុទ្ធសាស្ត្រសំខាន់ៗ **៥ ចំណុច** មានដូចខាងក្រោម ៖

- មិនយកថ្លៃស្នាក់នៅ ហូបចុក ដឹកជញ្ជូន ពីប្រតិភូកីឡាចូលរួមទាំងអស់ ។
- មិនលក់សំបុត្រចូលទស្សនាពិធីបើក-បិទ និងការប្រកួតគ្រប់ប្រភេទកីឡា ។
- មិនយកថ្លៃ "**សិទ្ធផ្សាយទូរទស្សន៍**" គ្រប់ប្រព័ន្ធផ្សព្វផ្សាយ ។
- មិនយកថ្លៃ **VISA** គ្រប់ប្រតិភូកីឡា និងមន្ត្រីបច្ចេកទេសអន្តរជាតិ មកពីគ្រប់ទិសទីជុំវិញពិភពលោក ។

- គោលការណ៍អូឡាំពិកអន្តរជាតិចង់បានគឺ "**ចំណាយតិចតែបង្កើតភាពអស្ចារ្យ**" ដូចនេះ តាមគម្រោងតួលេខចំណាយសរុបតិចជាងបណ្តាប្រទេសធ្វើម្ចាស់ផ្ទះរៀបចំមុនៗ ធ្វើឱ្យកម្ពុជាសម្រេចបានគោលដៅសន្សំសំចៃ គឺចំណាយតិចប៉ុន្តែពិតជាបង្កើតបានភាពអស្ចារ្យពិតប្រាកដ ។

**គ.** សូចនាករផែនការមេ និងផែនការយុទ្ធសាស្ត្រសម្រេចបានជោគជ័យលើសពីការរំពឹងទុក

- **ព្រះរាជពិធីប្រោសព្រះរាជទាន ព្រះអគ្គិជ័យកីឡា និងដំណើរគោចរដង្ហែភ្លើងគប់** ប្រព្រឹត្តទៅដោយរលូន សុវត្ថិភាព គគ្រឹកគគ្រេង ទាំងក្នុង និងក្រៅប្រទេស ផ្តល់នូវមហាកិត្តិយសជាតិដ៏ធំធេង និងសម្រែកគាំទ្រជាចលនាជាតិនិយម មោទនភាពជាតិខ្មែរ មោទនភាពកម្ពុជា ជាម្ចាស់ផ្ទះ កើតឡើង យ៉ាងកងរំពងពាសពេញ ព្រះរាជាណាចក្រកម្ពុជា។ ពិសេសពង្រឹងចំណងកាទូតកាន់តែជិតស្និតរឹងមាំ និងការគាំទ្រពេញទំហឹងពី រដ្ឋាភិបាល អាជ្ញាធរកីឡា ចលនាអូឡាំពិក ចលនាប៉ារ៉ាឡាំពិក អត្តពលិក ប្រជាជននៃបណ្តាប្រទេសអាស៊ីអាគ្នេយ៍ ដល់ព្រឹត្តិការណ៍ **SEA Games-ASEAN Para Games** ឆ្នាំ២០២៣ ដែលកម្ពុជាធ្វើជាម្ចាស់ផ្ទះ ។
- **ពិធីបើក-បិទ SEA Games-ASEAN Para Games ជាផ្លូវការ** គឺពិតជាបង្កើតបាននូវ "**ភាពភ្ញាក់ផ្អើល និងភាពអស្ចារ្យ**" ប្រកបដោយប្រណិតភាព និងភាពឥតខ្ចោះ។ ទស្សនីយភាព នៃពិធីបានជះឥទ្ធិពលពីកម្ពុជា ទៅគ្របដណ្តប់ប្រជាជាតិទូទាំងពិភពលោក ពិសេសភ្ញាក់ផ្អើលដល់ចលនាអូឡាំពិកអន្តរជាតិ-ប៉ារ៉ាឡាំពិកអន្តរជាតិ ដែលមានសមាជិក ២០៥ប្រទេស។ អ្វីដែលលើសពីការរំពឹងទុក ទី១: គឺអរិយធម៌អង្គរ របស់បុព្វបុរសខ្មែរ និងសក្តានុពលជាតិគ្រប់វិស័យត្រូវបានដាក់បង្ហាញយ៉ាងទាក់ទាញបំផុត ធ្វើឱ្យបរទេសកាន់តែស្គាល់បេះដូងខ្មែរ ពិតប្រាកដ។ ទី២ : គឺប្រែ ក្លាយផ្ទាំងទស្សនីយភាពពិធីបើក ពីកម្រិតស្តង់ដារព្រឹត្តិការណ៍ប្រកួតកីឡាតំបន់ ឬទ្វីប ទៅជាពិធីបើកកម្រិតស្តង់ដាអូឡាំពិកពិភពលោក ។
- **លទ្ធផលបច្ចេកទេស**: កម្ពុជាទទួលបានលទ្ធផលបច្ចេកទេសលើសពីការរំពឹងទុក ដែលប្រជាជនកម្ពុជាទាំងក្នុង និងក្រៅប្រទេស មានអារម្មណ៍ភ្ញាក់ផ្អើលពីសមត្ថភាពដ៏ខ្លាំងក្លា ទេពកោសល្យដ៏ប៉ិនប្រសព្វ ជំនាញវិជ្ជាជីវៈកីឡាដ៏គត់មត់ រួមជាមួយការបង្ហាញនូវអត្តចរិកសមរម្យ ឥរិយាបថថ្លៃថ្នូរ គោរពបទបញ្ជាការប្រកួត ក្រមសីលធម៌កីឡា គោលការណ៍លេងដោយយុត្តិធម៌របស់អត្តពលិកជាតិ ទើបអត្តពលិក SEA Games កម្ពុជាដណ្តើមបានមេដាយមាស៨១ ប្រាក់៧៤ និងសំរឹទ្ធ១២៧ សរុបចំនួន២៨២ ដែលជាកំណត់ត្រាប្រវត្តិសាស្ត្រខ្ពស់ជាងគេបំផុតសម្រាប់កម្ពុជា ដែលបានឈរចំណាត់ថ្នាក់ទី៤ ក្នុងចំណោម១១ប្រទេស បើធៀបជាមួយលទ្ធផលបច្ចេកទេសនៅក្នុងព្រឹត្តិការណ៍ SEA Games លើកទី៣១ ឆ្នាំ២០២២ នៅប្រទេសវៀតណាម ដែលកម្ពុជាទទួលបានមេដាយមាស៩ ប្រាក់១៣ និងសំរឹទ្ធ៤១ សរុបចំនួន៦៣ ប៉ុណ្ណោះ និងនៅចំណាត់ថ្នាក់ទី៨ ចំណោម១១ប្រទេសចូលរួម។ រីឯ អត្តពលិកមានពិការភាព ក៏បានបង្ហាញពីសមត្ថភាព ការតស៊ូ និងទេពកោសល្យជំនាញកីឡាយ៉ាង ប៉ិនប្រសព្វ ធ្វើឱ្យមហាជនកោតសរសើរ គោរពឱ្យតម្លៃគ្រប់ៗគ្នា។ ក្នុងនោះ លទ្ធផលបច្ចេកទេសក៏ បានទទួលលើសពីការគ្រោងទុក គឺមេដាយមាស៩ ប្រាក់១៩ និងសំរឹទ្ធ៤៥ សរុបចំនួន៧៣ កម្ពុជា ស្ថិតនៅចំណាត់ថ្នាក់លេខ៨ ក្នុងចំណោម១១ប្រទេសចូលរួម កើនឡើងជាង ASEAN Para Games លើកទី១១ នៅឥណ្ឌូនេស៊ី ដែលកម្ពុជាទទួលបានមេដាយមាស៧ ប្រាក់១០ និងសំរឹទ្ធ១១ សរុប ចំនួន២៨ ប៉ុណ្ណោះ។
- **ក្រសួងអប់រំ យុវជន និងកីឡា** ក៏បានសម្រេចជោគជ័យតាមគោលការណ៍កំណែទម្រង់វិស័យកីឡា លើយុទ្ធសាស្ត្រផ្តល់ថវិកាឧបត្ថម្ភប្រចាំឆ្នាំ ជូនសហព័ន្ធកីឡាជាតិ និងការកែទម្រង់ការប្រកួតកីឡាជាតិ ទើបជំរុញឱ្យអត្តពលិកជាតិ បង្កើនគុណផលកីឡារហូតទទួលបានលទ្ធផល ដោយនឹកស្មានមិនដល់ក្នុងការប្រកួតកីឡា **SEA Games- ASEAN Para Games** នាពេលនេះ។

- **កីឡាអត្តសញ្ញាណជាតិ** ត្រូវបានលើកកម្ពស់គុណតម្លៃខ្ពស់ត្រដែត ផ្សព្វផ្សាយពាសពេញប្រទេស និងលើឆាកអន្តរជាតិ ហើយកម្ពុជាក៏ដណ្តើមបានឧត្តមភាពមេដាយខ្ពស់លើប្រភេទកីឡាអត្តសញ្ញាណជាតិទាំងបីគឺ គុនខ្មែរ គុនល្បុក្កតោ និងអុកចត្រង្គ។ ពិសេសជាងនេះ គុនខ្មែរ និងគុនល្បុក្កតោ ត្រូវបានក្រុមប្រឹក្សាសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ អនុម័តនិងសម្រេចដាក់បញ្ចូលក្នុងធម្មនុញ្ញសហព័ន្ធកីឡាអាស៊ីអាគ្នេយ៍ **"SEAGF"** បានយ៉ាងជោគជ័យសម្រាប់អនាគតនៃការបន្តអភិវឌ្ឍកីឡាយុទ្ធគុនខ្មែរទាំងពីរ លើឆាកអន្តរជាតិ ។
- **ការទទួលបដិសណ្ឋារកិច្ច** ការស្នាក់នៅ ហូបចុក ដឹកជញ្ជូន សន្តិសុខ សណ្តាប់ធ្នាប់ សុខាភិបាល អំឡុងពេលប្រកួត បានប្រព្រឹត្តទៅយ៉ាងរលូនតាមការគ្រោងទុក និងមិនមានបញ្ហាអ្វីមួយកើតឡើង គួរឱ្យកត់សម្គាល់ឡើយ។ ផ្ទុយទៅវិញ យើងតែងទទួលបាននូវការកោតសរសើរ និងវាយតម្លៃខ្ពស់ ពីអ្នកចូលរួមទាំងអស់។ ពិសេសភូមិកីឡាបានបន្ថែមពិន្ទុឱ្យកម្ពុជា ជាប់ក្នុងប្រទេសម្ចាស់ផ្ទះដែល គោរពតាមស្តង់ដាស្នាក់នៅ ហូបចុក កម្រិតលក្ខខណ្ឌតម្រូវរបស់កីឡាអូឡាំពិក។
- **ទីលានប្រកួតកីឡាទាំងអស់** ស្ទើរតែ១០០% ក្នុងចំណោម ៣៧ប្រភេទកីឡាជាផ្លូវការ ត្រូវបានរៀបចំកម្រិតស្តង់ដាកីឡាអន្តរជាតិ និងគោរពតាមនិយាមនៃបទប្បញ្ញត្តិបច្ចេកទេសរបស់សហព័ន្ធកីឡាអន្តរជាតិ។ ពិសេសការបំពាក់ឧបករណ៍សម្ភារៈបច្ចេកទេស ឧបករណ៍សម្ភារៈវិនិច្ឆ័យការប្រកួត ឧបករណ៍បច្ចេកវិទ្យា កំណត់ពេលវេលា និងកំណត់ពិន្ទុ ការតុបតែងសោភ័ណភាពក្នុងទីលានប្រកួតស្របតាមទស្សនាទានកីឡាកម្រិតខ្ពស់។
- **ការផ្សព្វផ្សាយ និងព័ត៌មាន** ដែលមានអ្នកសារព័ត៌មានជាតិជាង ២០០០នាក់ និងអ្នកសារព័ត៌មានអន្តរជាតិជាង១០០០នាក់។ ពិធីបើក-បិទ និងសកម្មភាពប្រកួតគ្រប់ប្រភេទកីឡាទាំងអស់ ត្រូវបានរៀបចំផ្សាយផ្ទាល់ តាមទូរទស្សន៍ជាតិ-អន្តរជាតិ និងតាមសារព័ត៌មានជាតិ-អន្តរជាតិ ក៏ដូចជាតាមបណ្តាញសង្គមនានា ដោយផ្ទាល់ ពិសេសតាមរយៈ **"Tik Tok"** ក្នុងកម្រិតគុណភាពស្តង់ដាកីឡា និងស្តង់ដារចនារូបភាព **Digital** ដែលគ្របដណ្តប់លើឆាកជាតិ និងអន្តរជាតិ។
- **ការតុបតែង និងបំផុសការផ្សព្វផ្សាយពាណិជ្ជកម្ម** តាមទីសាធារណៈ ដងផ្លូវសាធារណៈ និង ទីលានប្រកួតតាមរាជធានី-ខេត្ត បានទាន់ពេលវេលា ប្រកបដោយសោភ័ណភាព និងផុសផុល គ្រប់ទីកន្លែង។ គ្រប់ទីតាំងសំខាន់ៗក្នុងនោះរួមមាន ទង់ជាតិខ្មែរ និងទង់ជាតិគ្រប់ប្រទេស **J-Flag, Banner, Billboard,** អំពូល**LED** តាមរង្វង់មូល ខ្លោងទ្វារ ជាដើម។ ការតុបតែងមានគុណភាព និងសោភ័ណភាពគួរជាទីទាក់ទាញផុសផុលគ្រប់ទីកន្លែង។
- **អ្នកស្ម័គ្រចិត្ត** ចូលរួមបម្រើសេវាគ្រប់គ្រាន់ ធ្វើការបានល្អប្រកបដោយស្មារតីជាម្ចាស់ផ្ទះ បង្ហាញនូវការយកចិត្តទុកដាក់ភ្ញៀវ ផ្តល់ស្នាមញញឹម រួសរាយរាក់ទាក់ ធ្វើឱ្យប្រតិភូកីឡាទាំងអស់កក់ក្តៅ កោតសរសើរ និងបង្ហាញនូវភាពអាឡោះអាល័យពេលបែកគ្នាទៀតផង។ ពិសេសអ្នកស្ម័គ្រចិត្ត និងប្រតិភូកីឡាទាំងអស់បានបង្កើតក្តីស្រលាញ់មិត្តភាព សាមគ្គីភាព និងបន្តរក្សាចំណងទាក់ទងគ្នា យ៉ាងជិតស្និទទៀតផង។
- ចំពោះកញ្ចប់ថវិការៀបចំ ត្រូវបានធានា និងផ្គត់ផ្គង់ទាន់ពេលវេលា ឈរលើគោលការណ៍ **"សន្សំសំចៃ តែបង្កើតភាពអស្ចារ្យ"** ដោយគោរពនីតិវិធីហិរញ្ញវត្ថុ យ៉ាងតម្លាភាព គណនេយ្យភាព សុច្ចរិតភាព និងភាពច្នៃប្រឌិតខ្ពស់សក្តិសមជាគណៈកម្មការជំនាញហិរញ្ញវត្ថុ ដែលទទួលខុសត្រូវខ្ពស់ ចំពោះមុខ **CAMSOC-CAMAPGOC** និងរាជរដ្ឋាភិបាល ពិតប្រាកដ។

- **កេរ្តិ៍ឈ្មោះកម្ពុជាលើឆាកអន្តរជាតិ**: បានលើកគុណតម្លៃទ្វេគុណ ដែលមិនអាចកាត់ថ្លៃបាន។ កម្ពុជាមានឈ្មោះបោះសម្លេងល្បីរន្ទឺ ពិសេសទាក់ទាញចំណាប់អារម្មណ៍មនុស្សជាតិជុំវិញពិភពលោក សម្លឹងមកកម្ពុជា (ព្រឹត្តិការណ៍កីឡាមិនគិតថ្លៃ និងបំផុសស្មារតីអូឡាំពិក កញ្ញា ប៊ូ សំណាង យ៉ាងធំធេងទូលំទូលាយ) ។ល។
- **នយោបាយការបរទេស និងការទូត**: កើនឡើងកាន់តែល្អប្រសើរ ដែលផ្តល់នូវកិត្តិយសជូនរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា។
- **សេដ្ឋកិច្ច**: ចំណេញហេដ្ឋារចនាសម្ព័ន្ធរូបវន្តជាមូលដ្ឋានគ្រឹះសេដ្ឋកិច្ចដ៏សំខាន់ ដូចជា "**ពហុកីឡដ្ឋានជាតិមរតកតេជោ**" ជាដើម។ ចំណេញលើការចំណាយផ្សព្វផ្សាយពាណិជ្ជកម្មតាមយុទ្ធសាស្ត្រលក់ "**កម្ពុជា**" ទៅពិភពលោក តាមរយៈព្រឹត្តិការណ៍ទាំងពីរនេះ។ ក្រុមហ៊ុនអន្តរជាតិមួយចំនួន បានចូលរួមសហការឧបត្ថម្ភ គាំទ្រដល់ព្រឹត្តិការណ៍ និងបានមើលឃើញសក្តានុពលសេដ្ឋកិច្ចកម្ពុជា ហើយក៏កំពុងស្វែងរកឱកាស វិនិយោគទុននៅកម្ពុជាផងដែរ។
- **សង្គម និងវប្បធម៌**: វប្បធម៌ អរិយធម៌ខ្មែរដ៏សម្បូរបែប ស៊ីជម្រៅ ទំនៀមទម្លាប់ប្រពៃណីដ៏ផូរផង់ របៀបរបបរស់នៅ ជីវភាពរស់នៅ ឥរិយាបថ សុជីវធម៌ខ្មែរ ត្រូវបានដាក់បង្ហាញ និងផ្សព្វផ្សាយ យ៉ាងទូលំទូលាយ ទាំងដោយផ្ទាល់ និងប្រយោល។ មនុស្សរាប់ម៉ឺន រាប់លាននាក់ ទាំងខ្មែរ ទាំងបរទេស ភ្ញាក់ផ្អើលនឹងអ្វីដែលជារតនសម្បត្តិរបស់ដូនតាខ្មែរ ទាំងសម្បត្តិរូបី ទាំងសម្បត្តិអរូបី ដើម្បីផ្តល់ជូនមនុស្សជាតិលើភពផែនដីនេះ។
- **ទេសចរណ៍**: ជាលើកទីមួយ ដែលពុំធ្លាប់មានក្នុងការបំផុះព័ត៌មានទេសចរណ៍ពីកម្ពុជាទៅពិភពលោក ធ្វើឱ្យគេស្គាល់ និងយល់ស៊ីជម្រៅដល់ក្នុងបេះដូងខ្មែរ និងភាពសម្បូរបែបដ៏ទាក់ទាញរបស់កម្ពុជា ដែលជា "**ព្រះរាជាណាចក្រវប្បធម៌**" "**ព្រះរាជាណាចក្រអច្ឆរិយៈ**" ដែលស្រូបបានមនុស្សមកទស្សនាកម្ពុជាផ្ទាល់ប្រមាណ ៥០ម៉ឺននាក់ អំឡុងពេលព្រឹត្តិការណ៍ទាំងពីរ និងជាង ២៦៣ាន់លាននាក់ តាមរយៈប្រព័ន្ធសង្គមផ្សព្វផ្សាយគ្រប់ទម្រង់។
- **ឥទ្ធិពលសង្គម**: ទស្សនជាតិនិយម ក្នុងស្មារតីឯកភាពជាតិ បានជ្រួតជ្រាបផុសផុលដល់ខ្មែរ ទាំងក្នុង និងក្រៅប្រទេស ដោយខ្មែរម្នាក់ៗមានមោទនភាពជាតិរបស់ខ្លួន "**ខ្មែរធ្វើបាន ហើយធ្វើបានអស្ចារ្យ**" ក្នុងនាមជាម្ចាស់ផ្ទះ។ ពិសេស យុវជនរាប់ម៉ឺននាក់ រួមទាំងអ្នកស្ម័គ្រចិត្ត បានក្លាយជាទូតសុឆន្ទៈ ពាំនាំនូវសារល្អៗទៅគ្រប់ទិសទីអំពីមហាជោគជ័យនៃព្រឹត្តិការណ៍ **SEA Games-ASEAN Para Games** ឆ្នាំ២០២៣។
- បាវចនា "**កីឡារស់ក្នុងសន្តិភាព**" បានជះឥទ្ធិពលដល់បេះដូងមនុស្សជាតិគ្រប់ៗរូប ឱ្យមើលឃើញគុណតម្លៃដ៏ខ្ពង់ខ្ពស់ ដែលមិនអាចកាត់ថ្លៃបាន គឺសន្តិភាព ដែលមនុស្សជាតិប្រាថ្នាចង់បានគ្រប់ៗទីកន្លែង និងគ្រប់ពេលវេលា។
- **មរតកកីឡាអាស៊ីអាគ្នេយ៍ និងកីឡាជនពិការអាស៊ាន "SEA Games-ASEAN Para Games 2023 Legacy"** បន្សល់ទុកនូវការចងចាំជាកំណត់ត្រាប្រវត្តិសាស្ត្រដ៏អស្ចារ្យក្នុង "**សករាជ តេជោសែន**" និងជាកិត្តិយស កិត្យានុភាពជាតិដ៏ឧត្តុង្គឧត្តមបំផុត។

## ឃ. សេចក្តីសន្និដ្ឋានព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រ

ព្រឹត្តិការណ៍កីឡាជាកំណត់ត្រាប្រវត្តិសាស្ត្រ **SEA Games** ដែលកម្ពុជារង់ចាំ ៦៤ឆ្នាំ និង **ASEAN Para Games** ដែលកម្ពុជារង់ចាំ ២២ឆ្នាំ បានសម្រេចជោគជ័យពេញលេញ និងល្បីរន្ទឺពាសពេញ ពិភពលោក ។

ចលនាអូឡាំពិកអន្តរជាតិ និងចលនាប៉ារ៉ាឡាំពិកអន្តរជាតិ បានវាយតម្លៃខ្ពស់ ចំពោះរាជរដ្ឋាភិបាល គណៈកម្មាធិការរៀបចំការប្រកួត ប្រជាជនកម្ពុជា ដែលបានប្រមូលអស់លទ្ធភាព សមត្ថភាព និង ឆន្ទៈមោះមុត បង្កើតភាពអស្ចារ្យក្នុងចលនាអូឡាំពិក-ប៉ារ៉ាឡាំពិក ដោយគោរពតាមស្តង់ដាអូឡាំពិកអន្តរជាតិ-ប៉ារ៉ាឡាំពិកអន្តរជាតិយ៉ាងល្អប្រសើរ។

គណៈកម្មាធិការជាតិអូឡាំពិក និងប៉ារ៉ាឡាំពិកគ្រប់ប្រទេសជាសមាជិកចូលរួម បានកោតសរសើរ និងវាយតម្លៃខ្ពស់ចំពោះការលើកកម្ពស់ព្រឹត្តិការណ៍ **SEA Games-ASEAN Para Games** ឈាន ដល់កម្រិតអូឡាំពិក និងប៉ារ៉ាឡាំពិកអន្តរជាតិ និងផ្តល់នូវភាពអស្ចារ្យឱ្យកាន់តែល្បីល្បាញ និងទាក់ទាញ ការគាំទ្រយ៉ាងខ្លាំង ពីគ្រប់ទិសទី ។ ក្នុងនោះដែរ **ASEAN Para Games** ក៏បានទទួលស្គាល់ ស្តង់ដារៀបចំល្អប្រសើរជាងលើកមុនៗ ហើយផ្តល់តម្លៃដល់អត្តពលិកជនមានពិការភាពខ្ពស់ ក្នុងនាមជា ម្ចាស់ផ្ទះរៀបចំ។ សិទ្ធិសេរីភាព និងសមត្ថភាពជនមានពិការភាព ត្រូវបានបង្ហាញ និងទទួលស្គាល់ ពាសពេញប្រទេស និងលើឆាកអន្តរជាតិ។

តាមការប្រមូលទិន្នន័យពីប្រព័ន្ធផ្សព្វផ្សាយ បានបំបែកឯកត្តកម្មនៃការទាក់ទាញអ្នកទស្សនា ច្រើនជាងគេ បើធៀបទៅនឹងព្រឹត្តិការណ៍ **SEA Games** មុនៗ ក្នុងនោះអ្នកចូលទស្សនាតាម **"Tik Tok"** ក្នុងរយៈពេលមួយខែពេញ មានចំនួនប្រមាណ ២៦៣ពាន់លាននាក់ ជុំវិញពិភពលោក និងមានអ្នក ទស្សនាតាមទូរទស្សន៍ ក្នុងរយៈពេលនៃការប្រកួត មានចំនួន៥៥០លាននាក់ ជុំវិញពិភពលោក។ រីឯអ្នកគាំទ្រ និងអ្នកទេសចរគាំទ្រ មកចូលរួមផ្ទាល់គិតតាមជើងហោះហើរ សណ្ឋាគារ និងក្រុមហ៊ុន ទេសចរណ៍នានា និងគិតតាមចំនួនចូលរួមទស្សនា ពិធីបើក-បិទ និងទស្សនាការប្រកួតបាល់ទាត់ ក៏ដូច ការប្រកួតកីឡាផ្សេងៗទៀត តាមការប៉ាន់ប្រមាណគឺ ទេសចរក្នុងស្រុកប្រមាណជាង ៤០ម៉ឺននាក់ និង ទេសចរបរទេសប្រមាណជាង ២០ម៉ឺននាក់ ក្នុងរយៈពេល ជាង៣០ថ្ងៃ អំឡុងពេលប្រកួត មុនពេល ប្រកួត និងក្រោយពេលប្រកួត។ ដូចនេះ អ្នកគាំទ្រចាត់ទុកជាអ្នកទេសចរចូលរួមសរុបប្រមាណពី ៥០ម៉ឺននាក់ ទៅ ៦០ម៉ឺននាក់។

បើគិតក្នុងក្របខ័ណ្ឌម៉ាក្រូព្រឹត្តិការណ៍ គឺជាជោគជ័យដ៏អស្ចារ្យ និងនាំមកនូវមហាកិត្តិយស កិត្យានុភាពជាតិល្បីរន្ទឺពាសពេញពិភពលោក ប៉ុន្តែអ្វីដែលជោគជ័យពិតប្រាកដ គឺសន្ទុះនៃការគាំទ្រ យ៉ាងគគ្រឹកគគ្រេងរបស់មហាជនជាតិ-អន្តរជាតិ គ្រប់ពេលវេលា និងគ្រប់ទិសទី។

ជារួម ការរៀបចំព្រឹត្តិការណ៍កីឡាអាស៊ីអាគ្នេយ៍លើកទី៣២ និងអាស៊ានប៉ារ៉ាហ្គេមលើកទី១២ ឆ្នាំ២០២៣ ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចតេជោ នាយករដ្ឋមន្ត្រី** ប្រព្រឹត្តដោយរលូន និងទទួលជោគជ័យជាប្រវត្តិសាស្ត្រ និងបានពង្រឹងស្មារតី សន្តិភាព ឯកភាពជាតិ និងស្ថិរភាព ស្របតាមបុព្វបទ "**កីឡារស់ក្នុងសន្តិភាព**"។

## III. សមិទ្ធផលការងារសំខាន់ៗ ប្រចាំអាណត្តិទី៨ ឆ្នាំ២០២២-២០២៦

- **ឆ្នាំ២០២២**:
  - គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ចាត់ទុកឆ្នាំ២០២២ គឺជាឆ្នាំដ៏មមាញឹក និងសកម្មបំផុតក្នុងការរៀបចំគ្រប់លក្ខណៈសម្បត្តិ ត្រៀមរៀបចំព្រឹត្តិការណ៍ **SEA Games** លើកទី៣២ និង **ASEAN Para Games** លើកទី១២។
  - ក្រៅពីការងារស្នូលជាប្រក្រតីរបស់ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា គឺថ្នាក់ដឹកនាំមន្ត្រីគណៈ-កម្មាធិការជាតិអូឡាំពិកកម្ពុជា ជាកម្លាំងស្នូលក្នុងការដឹកនាំអនុវត្តផែនការមេ និងផែនការសកម្មភាព **SEA Games-ASEAN Para Games** ទាំងស្រុង។

- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា បានរៀបចំមហាសន្និបាតក្រុមប្រឹក្សាអូឡាំពិកអាស៊ី **“OCA”** លើកទី៤១ នាថ្ងៃទី៤ ខែតុលា ឆ្នាំ២០២២ នៅសណ្ឋាគារសុខាភ្នំពេញ ដោយទទួលបានជោគជ័យជាប្រវត្តិសាស្ត្ររបស់ចលនាអូឡាំពិកកម្ពុជា។
- ក្នុងនោះការចូលរួមប្រកួតកីឡា **SEA Games** លើកទី៣២ និងទទួលពិធីផ្ទេរសិទ្ធិផ្ទេរទង់ **SEA Games** ពីវៀតណាមមកកម្ពុជា ក៏ទទួលបានជោគជ័យ និងប្រសិទ្ធភាពការងារខ្ពស់ ប្រកបដោយការទទួលខុសត្រូវរបស់ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ផងដែរ។
- ចូលរួមមហាសន្និបាត **“OCA”** និងបានចុះហត្ថលេខាលើកិច្ចសន្យាទីក្រុងម្ចាស់ផ្ទះនៅ **Dubai** សម្រាប់ **AYG** ឆ្នាំ២០២៩។

- **ឆ្នាំ២០២៣**:

ជាឆ្នាំដំណើរការធ្វើម្ចាស់ផ្ទះរៀបចំព្រឹត្តិការណ៍ **SEA Games-ASEAN Para Games** ដោយស្មារតីភាពជាអ្នកដឹកនាំល្អរបស់ថ្នាក់ដឹកនាំមន្ត្រី គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ប្រកបដោយឆន្ទៈប្ដេជ្ញាចិត្តខ្ពស់ ទើបព្រឹត្តិការណ៍ជាប្រវត្តិសាស្ត្រដែលរង់ចាំ ៦៤ឆ្នាំ បានទទួលជោគជ័យមិនគួរឱ្យជឿដូចបានអធិប្បាយខាងលើស្រាប់។

- **ឆ្នាំ២០២៤**:

បន្តស្មារតីបុរេសកម្ម និងបន្តការអភិវឌ្ឍចលនាអូឡាំពិកកម្ពុជាប្រកបដោយចីរភាព និង បរិយាប័ន្ន។ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា បានដាក់ចេញនូវផែនការយុទ្ធសាស្ត្រថ្មីៗ ឆ្ពោះទៅពង្រឹងអភិបាលកិច្ចល្អ និងសមត្ថភាព គ្រប់គ្រងដឹកនាំរបស់សហព័ន្ធកីឡាជាតិ ក្រោយចប់ **SEA Games-ASEAN Para Games**។

- ដាក់ចេញនូវគោលការណ៍កែទម្រង់សហព័ន្ធកីឡាជាតិ តាមអភិក្រម **"អគ្គលេខាធិការល្អ សហព័ន្ធដំណើរការល្អ"** និង **"គ្រូបង្វឹកល្អ កីឡាករខ្លាំងពូកែ"**។
- បានដឹកនាំចូលរួមការប្រកួត **Asian Games** នៅប្រទេសចិន និង **Olympic Summer Games** នៅទីក្រុងបារីស បានដោយជោគជ័យ។
- បានជួយរៀបចំការប្រកួតកីឡាជាតិលើកទី៤ ជាមួយក្រសួងអប់រំ យុវជន និងកីឡា ដោយជោគជ័យ។
- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា បានទទួលភារកិច្ចថ្មីៗពីរាជរដ្ឋាភិបាល ពិសេសពី **សម្តេចមហាបវរធិបតី នាយករដ្ឋមន្ត្រី** ដឹកនាំ **"ការប្រកួតកីឡាយុទ្ធគុនចម្រុះខ្មែរបុរាណពានរង្វាន់សម្តេចបវរធិបតី"** និងដឹកនាំគណៈកម្មការសិក្សាស្រាវជ្រាវ **"គម្ពីរអាថ៌កំបាំង យុទ្ធគុនដូនតាខ្មែរ"**។
- ទិវារត់ប្រណាំងពាក់កណ្ដាលម៉ារ៉ាតុងអន្តរជាតិអង្គរលើកទី២៩ ឆ្នាំ២០២៤ នេះ អាចចាត់ទុកជាកំណត់ត្រាប្រចាំព្រឹត្តិការណ៍ដ៏សំខាន់ ដោយសារ **សម្ដេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានផ្ដល់កិត្តិយស ដ៏ខ្ពង់ខ្ពស់បំផុតចូលរួមជាអធិបតី និងចូលរួមរត់កម្សាន្ត ៥គ.ម ទៀតផង។

- **ឆ្នាំ២០២៥**:

- ដឹកនាំប្រតិភូកីឡាកម្ពុជាចូលរួមការប្រកួតកីឡាយុវជនលើកទី៤ នៅបារ៉ែន និងបានដោះស្រាយបញ្ហាជាមួយ **“OCA”** ក្នុងការលើកពេលរៀបចំ **“AYG”** ពីឆ្នាំ២០២៩ មកឆ្នាំ២០៣១ វិញ។
- រាជរដ្ឋាភិបាលបានអនុញ្ញាតតាមតាមសំណើរបស់ **“OCA”** ផ្ដល់សិទ្ធិជូន គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ធ្វើជាម្ចាស់ផ្ទះ **“AYG”** លើកទី៥ ឆ្នាំ២០៣១។

- រាជរដ្ឋាភិបាលបានចេញអនុក្រឹត្យ ស្តីពីការបង្កើតគណៈកម្មាធិការជាតិរៀបចំការប្រកួតកីឡាយុវជនអាស៊ី លើកទី៥ ឆ្នាំ២០៣១។ និងកីឡាយុវជនអាស៊ីប៉ារ៉ាហ្គេម ឆ្នាំ២០២៩ រួចហើយ នៅតែការតែងតាំងសមាសភាពដឹកនាំគណៈកម្មាធិការជាតិនេះតែប៉ុណ្ណោះ។
- គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា បានបំពេញកាតព្វកិច្ចចូលរួមលើកទង់ជាតិ និងពិធីបើកការប្រកួតកីឡា **SEA Games** លើកទី៣៣ នៅប្រទេសថៃ តាមស្មារតីគោរពជម្មនុញ្ញ **SEA Games** និងការទូតកីឡាពេញលេញ ប៉ុន្តែប្រតិភូកីឡាកម្ពុជាត្រូវដកត្រឡប់មកមាតុភូមិវិញ ដោយមិនចូលរួមប្រកួតដោយសារសំពាធនៃសង្គ្រាមឈ្លានពានពីប្រទេសម្ចាស់ផ្ទះ។
- គ.ជ.អ.ក បានទទួលជំនួយដ៏សន្ធឹកសន្ធាប់ពីអង្គការសាមគ្គីអូឡាំពិក **"OS"** តាមរយៈក្រុមប្រឹក្សាអូឡាំពិកអាស៊ី **"OCA"** ជួយដល់ជនភាសសឹកពីសង្គ្រាមឈ្លានពាន។
- បានចុះអានុស្សរណៈយោគយល់គ្នា **"MOU"** រវាងគណៈកម្មាធិការជាតិអូឡាំពិករុស្ស៊ី និងកម្ពុជា ដើម្បីពង្រឹងកិច្ចសហប្រតិបត្តិការ និងជួយគ្នាទៅវិញទៅមកលើកកាទូតកីឡា និងអភិវឌ្ឍបច្ចេកទេសកីឡាកម្រិតខ្ពស់។
- បានចុះហត្ថលេខាលើកិច្ចសន្យាទីក្រុងម្ចាស់ផ្ទះ **(HCC)** សម្រាប់រៀបចំម្ចាស់ផ្ទះ **AYG** លើកទី៥ ឆ្នាំ២០៣១ នាថ្ងៃទី២៦ ខែមករា ឆ្នាំ២០២៦ នៅទីក្រុង **Tashkent** ប្រទេស **Uzbekistan**។

ចំពោះការងារស្នូលរបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា សម្រេចបានពេញមួយអាណត្តិតាមការឧបត្ថម្ភពីអង្គការសាមគ្គីអូឡាំពិកដូចខាងក្រោម៖

១- បើកវគ្គរដ្ឋបាលកីឡាបាន ១២វគ្គ សិក្ខាកាមចំនួន ៤២០នាក់។

២- បើកវគ្គគ្រូបង្វឹកជំនាញដល់សហព័ន្ធកីឡាជាតិចំនួន ១២ប្រភេទកីឡា ដោយមានគ្រូជំនាញពីសហព័ន្ធកីឡាអន្តរជាតិ។

៣- រៀបចំព្រឹត្តិការណ៍អប់រំអូឡាំពិក និងបំផុសចលនាកីឡាក្នុងសង្គម **"កីឡាដើម្បីទាំងអស់គ្នា"** បាន ៨ព្រឹត្តិការណ៍។

៤- រៀបចំព្រឹត្តិការណ៍កីឡាជំនាញអន្តរជាតិ និងកីឡាមហាជនប្រមាណ ២៨លើក។

## IV. បញ្ហាប្រឈម

១- ស្ថានភាពនយោបាយសេដ្ឋកិច្ចពិភពលោករំជើបរំជួលប្រែប្រួលហើយមិនប្រាកដប្រជា ពិសេសវិបត្តិសេដ្ឋកិច្ចសកល នៃការប្រកួតប្រជែងនៃមហាអំណាចសេដ្ឋកិច្ច និងសង្គ្រាមបានជះឥទ្ធិពលដល់កិច្ចការអភិវឌ្ឍចលនាអូឡាំពិក ទាំងមូល និងដោយឡែកនៅកម្ពុជា។

២- ស្ថានភាពព្រំដែនកម្ពុជា-ថៃ មិនទាន់មានជំនឿថាមានបទឈប់បាញ់យូរអង្វែង និងអចិន្ត្រៃយ៍នៅឡើយ។

៣- អភិបាលកិច្ចល្អ ធនធានមនុស្ស និងលទ្ធភាពឧបត្ថម្ភគាំទ្រនៅមានកម្រិត។

៤- សហព័ន្ធកីឡាជាតិនៅមានតម្រូវការមូលដ្ឋានជាច្រើន **"Basic needs"** ដែលកំពុងរាំងស្ទះការអភិវឌ្ឍស្តង់ដាកីឡាអន្តរជាតិ ដូចជាអភិបាលកិច្ចមិនរឹងមាំ ធនធានមនុស្សជំនាញកីឡាខ្វះខាត ធនធានកីឡាករខ្វះខាត ឧបករណ៍សម្ភារៈកីឡាស្តង់ដាខ្វះខាត ទីលានកីឡាស្តង់ដាខ្វះខាត និងការឧបត្ថម្ភគាំទ្រមិនទាន់ឆ្លើយតបតម្រូវការលក្ខខណ្ឌ នៃការអភិវឌ្ឍជំនាញកីឡារបស់ខ្លួននៅឡើយ។

៥- កិច្ចសហការរវាងភាគីពាក់ព័ន្ធនិងស្មារតីការងារជាក្រុមនៅមានកម្រិត ស្ថានភាពខ្លះមកពីខ្វះការយោគយល់ និងទទួលខុសត្រូវ។

## V. ដំណោះស្រាយ

១- ខិតខំពង្រឹងសមត្ថភាពជំនាញវិជ្ជាជីវៈទាំងផ្នែករឹងនិងផ្នែកទន់ ដើម្បីបង្កើនផលិតភាព និងធនធានដោយឈរ លើជំហរខ្លួនឯង រឹងមាំដោយខ្លួនឯង។

២- បន្តធ្វើការកំណែទម្រង់ស៊ីជម្រៅលើរបៀបរបបការងារ អភិបាលកិច្ចល្អប្រកបដោយតម្លាភាព គណនេយ្យភាព និងការទទួលខុសត្រូវខ្ពស់។

៣- ជំរុញការបណ្តុះបណ្តាលសមត្ថភាពជំនាញ ឱ្យមានមូលធនមនុស្សច្បាស់លាស់គ្រប់គ្រាន់ក្នុងវិស័យកីឡា។

៤- ស្វែងរកលទ្ធភាពកៀរគរចំណូល ដោយពិចារណាលើការរៀបចំបង្កើតឧស្សាហកម្មកីឡាលើមុខងារណាមួយដែលអាចធ្វើបាន ដើម្បីធានាចីរភាពនៃការអភិវឌ្ឍចលនាអូឡាំពិកកម្ពុជា។

៥- បន្តធ្វើសុខដុមនីយកម្មការងារជាមួយដៃគូអភិវឌ្ឍកីឡាជាតិ និងអន្តរជាតិ ពិសេសជាមួយភាគីពាក់ព័ន្ធ ប្រកបដោយប្រសិទ្ធភាពខ្ពស់ ឆ្ពោះទៅរកគោលដៅតែមួយ គឺអភិវឌ្ឍកីឡាជាតិ និងចលនាអូឡាំពិក។

## VI. សេចក្តីសន្និដ្ឋាន

អាណត្តិទី៨ ប្រចាំឆ្នាំ២០២២-២០២៦ ពិតជាអាណត្តិពិសេស ជាកំណត់ត្រាប្រវត្តិសាស្ត្រចលនាអូឡាំពិកកម្ពុជាដែលបានសាងស្នាដៃដ៏អស្ចារ្យ និងជារបត់នៃសម័យរីកចម្រើនខ្លាំងរបស់ចលនាអូឡាំពិកកម្ពុជា ក្នុងការរៀបចំព្រឹត្តិការណ៍ ប្រកួតកីឡា **SEA Games** លើកទី៣២ និង **ASEAN Para Games** លើកទី១២ ឆ្នាំ២០២៣ បានទទួលជោគជ័យដ៏ត្រចះត្រចង់ និងល្បីល្បាញលើឆាកជាតិ និងអន្តរជាតិ។

## VII. ចំពោះទិសដៅបន្តសម្រាប់អាណត្តិទី៩ ប្រចាំឆ្នាំ២០២៦-២០៣០ មានក្នុងឯកសារឧបសម្ព័ន្ធ ស្តីពីផែនការយុទ្ធសាស្ត្របន្តអាណត្តិទី៩ ។

**កីឡារស់ក្នុងសន្តិភាព! អរគុណសន្តិភាព!**

| | |
|---|---|
| **បានឃើញ និងឯកភាព** | **ជ.គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា** |
| **ប្រធាន** | **អគ្គលេខាធិការ** |
| **ថោង ខុន** | **វ៉ាត់ ចំរើន** |
| **ទេសរដ្ឋមន្ត្រីទទួលបន្ទុកបេសកកម្មពិសេស** | |

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា

# របាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់អាណត្តិទី៨ ឆ្នាំ២០២២-២០២៦
# និងទិសដៅការងារអាណត្តិទី៩ ឆ្នាំ២០២៦-២០៣០

ដើម្បីធានាឱ្យការគ្រប់គ្រងដឹកនាំ និងការអភិវឌ្ឍចលនាអូឡាំពិកកម្ពុជា ប្រព្រឹត្តទៅប្រកបដោយស្ថិរភាព ប្រសិទ្ធភាព តម្លាភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា បានកំណត់ចក្ខុវិស័យ បេសកកម្ម គោលបំណង និងយុទ្ធសាស្ត្រអាទិភាព និងធ្វើបុរេសកម្មឆ្ពោះទៅរកយុទ្ធសាស្ត្រជំរុញ និងកែទម្រង់ស៊ីជម្រៅឈានទៅធ្វើទំនើបកម្មចលនាអូឡាំពិកកម្ពុជា អនុលោមតាមធម្មនុញ្ញអូឡាំពិក និងយុទ្ធសាស្ត្រ បញ្ចកោណ ដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។

ដើម្បីជម្រុញការអភិវឌ្ឍចលនាអូឡាំពិកកម្ពុជាប្រកបដោយចីរភាព និងបរិយាបន្នសម្រាប់អាណត្តិទី៩ ប្រចាំឆ្នាំ ២០២៦-២០៣០ ការគ្រប់គ្រងហិរញ្ញវត្ថុត្រូវដំណើការណ៍អនុវត្តតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍចលនាអូឡាំពិកកម្ពុជា សម្រាប់អាណត្តិថ្មីឱ្យបានល្អ។ កាគ្រប់គ្រងហិរញ្ញវត្ថុ គឺជាកត្តាស្នូលមួយសម្រាប់ធានាឱ្យការអនុវត្តកម្មវិធី និងសកម្មភាពនានា ប្រព្រឹត្តទៅបានដោយប្រសិទ្ធភាព និងទទួលបានលទ្ធផលល្អប្រសើរ។

## ១. លទ្ធផលការងារហិរញ្ញវត្ថុក្នុងអាណត្តិទី៨ ឆ្នាំ២០២២-២០២៦

ក្នុងអាណត្តិទី៨កន្លងមក ការងារហិរញ្ញវត្ថុរបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ត្រូវបានអនុវត្តដោយគោរពតាមគោលការណ៍តម្លាភាព វិន័យហិរញ្ញវត្ថុ និងគណនេយ្យភាព ស្របតាមគោលការណ៍ណែនាំស្តីពីអភិបាលកិច្ចល្អលើផ្នែកហិរញ្ញវត្ថុរបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិ “IOC” អង្គការសាមគ្គីអូឡាំពិក “OS” និងក្រុមប្រឹក្សាអូឡាំពិកអាស៊ី “OCA” ។

ក្រៅពីការគាំទ្រថវិកាពីរាជរដ្ឋាភិបាល ក៏មានការឧបត្ថម្ភពីសប្បុរសជន និងក្រុមហ៊ុនឯកជននានាដែលបានចូលរួមចំណែកគាំទ្រសកម្មភាពចលនាអូឡាំពិកកម្ពុជា។ ជាមួយគ្នានេះគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក៏ទទួលបានការឧបត្ថម្ភគាំទ្រហិរញ្ញវត្ថុពីអង្គការកីឡាអន្តរជាតិដូចជា **គណៈកម្មាធិការអូឡាំពិកអន្តរជាតិ IOC (International Olympic Committee) ក្រុមប្រឹក្សាអូឡាំពិកអាស៊ី OCA (Olympic Council of Asia)** និង**អង្គការសាមគ្គីអូឡាំពិក OS (Olympic Solidarity)** ជារៀងរាល់ឆ្នាំផងដែរ។

ថវិកាទាំងនេះត្រូវបានប្រើប្រាស់ដើម្បីគាំទ្រសកម្មភាពប្រចាំថ្ងៃលើគោលដៅសំខាន់ៗដូចខាងក្រោម៖

- គាំទ្រសកម្មភាពរដ្ឋបាល
- គាំទ្រការអនុវត្តគម្រោងកម្មវិធី សកម្មភាពកីឡា មនុស្សធម៌ ការងារបណ្តុះបណ្តាល និងអភិវឌ្ឍធនធានមនុស្ស
- គាំទ្រការចំណាយសម្រាប់បដិសណ្ឋារកិច្ច ប្រជុំក្នុង និងក្រៅប្រទេស និងការងារជួសជុលថែទាំជាដើម។

ក្នុងឆ្នាំ២០២៥ បានអនុវត្តសវនកម្មចំនួន ២លើក រួមមាន៖

១. ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ "Financial Audit" ប្រចាំឆ្នាំ២០២៤ ដោយក្រុមសវនកម្មឯករាជ្យ និងអន្តរជាតិ Morison Kak MKA ទទួលស្គាល់ដោយគណៈកម្មាធិការអូឡាំពិកអន្តរជាតិ អង្គការសាមគ្គីអូឡាំពិក និងក្រុមប្រឹក្សាអូឡាំពិកអាស៊ី។

២. ការធ្វើសវនកម្មលើកិច្ចប្រតិបត្តិការ "Performance Audit" សម្រាប់អាណត្តិទី៨ ឆ្នាំ ២០២២-២០២៦ ដោយក្រុមសវនកម្មឯករាជ្យ និងអន្តរជាតិ Mazars Forvis ចាត់តាំងផ្ទាល់ដោយគណៈកម្មាធិការអូឡាំពិកអន្តរជាតិ អង្គការសាមគ្គីអូឡាំពិក និងក្រុមប្រឹក្សាអូឡាំពិកអាស៊ី។

លទ្ធផលក្រុមសវនកម្មទាំងពីរបានបញ្ជាក់ថា គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា បានអនុវត្តត្រឹមត្រូវស្របតាមគោលការណ៍ និងនីតិវិធីហិរញ្ញវត្ថុរបស់អូឡាំពិកអន្តរជាតិ ក៏ដូចជាប្រតិបត្តិការការងារស្របតាមគោលការណ៍ណែនាំស្តីពីអភិបាលកិច្ចល្អលើផ្នែកហិរញ្ញវត្ថុរបស់ IOC និងធម្មនុញ្ញអូឡាំពិក។

## តារាងលទ្ធផលចំណូល ចំណាយ អាណត្តិទី៨ ឆ្នាំ២០២២-២០២៦

### ក. ចំណូលក្នុង អាណត្តិទី៨

| ល.រ | បរិយាយ | ចំនួន |
|---|---|---|
| ១ | ហិរញ្ញប្បទានរដ្ឋបាលប្រចាំឆ្នាំ និងថវិកាគម្រោងកម្មវិធីពីគណៈកម្មាធិការអូឡាំពិកអន្តរជាតិ IOC (International Olympic Committee) និងអង្គការសាមគ្គីអូឡាំពិក OS (Olympic Solidarity) | ១,១២៣,០៤៣.00 ដុល្លារ |
| ២ | ហិរញ្ញប្បទានរដ្ឋបាលប្រចាំឆ្នាំ និងថវិកាគម្រោងកម្មវិធីពីក្រុមប្រឹក្សាអូឡាំពិកអាស៊ី OCA (Olympic Council of Asia) | ៥៧៥,០៥៣.00 ដុល្លារ |
| ៣ | ចំណូលពីប្រភពផ្សេងៗក្រៅចលនាអូឡាំពិក | ៩២,២២៣.២៣ ដុល្លារ |
| **សរុបចំណូល៖** | | **១,៧៩០,៣១៩.២៣ ដុល្លារ** |

### ខ. ចំណាយក្នុងអាណត្តិទី៨

| ល.រ | បរិយាយ | ចំនួន |
|---|---|---|
| ១ | សកម្មភាពរដ្ឋបាល | ៦១៦,១៤៥.៥០ ដុល្លារ |
| ២ | អនុវត្តគម្រោងកម្មវិធី សកម្មភាពកីឡា មនុស្សធម៌ និងអភិវឌ្ឍធនធានមនុស្ស | ១,០៥៤,៨៩៦.១១ ដុល្លារ |
| ៣ | ចំណាយលើការប្រជុំ និងការជួសជុលថែទាំ ។ល។ | ៨២,៧៥៤.៦២ ដុល្លារ |
| **សរុបចំណាយ៖** | | **១,៧៥៣,៧៩៦.២៣ ដុល្លារ** |

### គ. សមតុល្យចុងគ្រាក្នុងអាណត្តិទី៨

| ល.រ | បរិយាយ | ចំនួន |
|---|---|---|
| ១ | យោងសំណល់ឆ្នាំ២០២១ | ៥,២៨២.00 ដុល្លារ |
| ២ | ចំណូលអាណត្តិទី៨ | ១,៧៩០,៣១៩.២៣ ដុល្លារ |
| ៣ | ចំណាយសរុបអាណត្តិទី៨ | (១,៧៥៣,៧៩៦.២៣ ដុល្លារ) |
| **សរុបសំណល់អាណត្តិទី៨ ចុងឆ្នាំ២០២៥៖** | | **៤១,៨០៥.00 ដុល្លារ** |

### គំនូសសញ្ញាចំណូលអាណត្តិទី៨ សរុប ១,៧៩០,៣១៩.២៣ ដុល្លារ




- ចំណូលពី OCA៖ ៣២%
- ចំណូលពី IOC-OS ៖ ៦៣%
- ប្រភពផ្សេងៗ៖ ៥%

ប្រភពចំណូលមួយភាគធំបានពីអង្គការសោមគ្គីអូឡាំពិក (OS) សម្រាប់ធ្វើសកម្មភាពអប់រំបណ្តុះបណ្តាល និងការងារបំប៉នបន្ថែមកម្មវិធីហ្វឹកហាត់ត្រៀមប្រកួតកីឡាអន្តរជាតិ។

### គំនូសសញ្ញាចំណាយអាណត្តិទី៨ សរុប ១,៧៥៣,៧៩៦.២៣ ដុល្លារ




- ចំណាយរដ្ឋបាល៖ ៣៥%
- ចំណាយដាក់ស្តែងតាមកម្មវិធី៖ ៦០%
- ចំណាយកិច្ចប្រជុំ ជួសជុលថែទាំ និងផ្សេងៗ៖ ៥%

ថវិកាចំណាយទាំងអស់ គ្រប់កម្មវិធីតែងតែមានការធ្វើសវនកម្មដោយស្ថាប័នសវនកម្មអន្តរជាតិឯករាជ្យ ដើម្បីធ្វើការត្រួតពិនិត្យ និងវាយតម្លៃលើការប្រើប្រាស់ថវិកាឱ្យមានភាពត្រឹមត្រូវ និងតម្លាភាព។ លទ្ធផលសវនកម្មនេះ គឺជាមូលដ្ឋានបង្អែកយ៉ាងសំខាន់របស់អង្គការអន្តរជាតិក្នុងការពិនិត្យ អនុម័ត និងផ្តល់ថវិកាគាំទ្របន្តសម្រាប់ឆ្នាំបន្ទាប់។

តាមរយៈការគ្រប់គ្រងថវិកាប្រកបដោយប្រសិទ្ធភាពនេះ បានធ្វើឱ្យសកម្មភាពកីឡាជាតិអាចអនុវត្តទៅបានដោយរលូន និងទទួលបានការជឿទុកចិត្តពីដៃគូជាតិ និងអន្តរជាតិ។

ក្រៅពីនេះរាជរដ្ឋាភិបាលតាមរយៈក្រសួងអប់រំ យុវជន និងកីឡា និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានផ្តល់ការធានាចំណាយលើការប្រើប្រាស់ទឹក-ភ្លើង ក្នុងអគារគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាជារៀងរាល់ឆ្នាំ។

## ២. ទិសដៅការងារហិរញ្ញវត្ថុអាណត្តិទី៩ ឆ្នាំ២០២៦-២០៣០

សម្រាប់អាណត្តិថ្មីខាងមុខ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា នឹងបន្តពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យកាន់តែមានប្រសិទ្ធភាព និងតម្លាភាពបន្ថែមទៀត ដោយផ្តោតលើទិសដៅសំខាន់ៗដូចខាងក្រោម៖

- បន្តពង្រឹងប្រព័ន្ធគ្រប់គ្រង និងត្រួតពិនិត្យហិរញ្ញវត្ថុឱ្យមានភាពត្រឹមត្រូវ និងតម្លាភាព
- ពង្រីកប្រភពថវិកា តាមរយៈការទាក់ទាញការឧបត្ថម្ភពីវិស័យឯកជន និងដៃគូអភិវឌ្ឍន៍
- បន្តពង្រឹងកិច្ចសហការជាមួយអង្គការកីឡាអន្តរជាតិ ដើម្បីទទួលបានការគាំទ្រថវិកាបន្ថែម
- ប្រើប្រាស់ថវិកាឱ្យមានប្រសិទ្ធភាពខ្ពស់ ក្នុងការគាំទ្រការអភិវឌ្ឍសហព័ន្ធកីឡាជាតិ ការហ្វឹកហាត់ និងការបណ្តុះបណ្តាលធនធានមនុស្ស។

**៣. សេចក្តីសន្និដ្ឋាន**

ការគ្រប់គ្រងហិរញ្ញវត្ថុក្នុងអាណត្តិទី៨កន្លងមក បានអនុវត្តដោយគោរពតាមគោលការណ៍តម្លាភាព វិន័យហិរញ្ញវត្ថុ និងគណនេយ្យភាព ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាព ក្នុងការគាំទ្រដល់ការអភិវឌ្ឍវិស័យកីឡាជាតិ និងលើកកម្ពស់ចលនាអូឡាំពិកកម្ពុជា។

សម្រាប់អាណត្តិទី៩ ខាងមុខ គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា នឹងបន្តពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុឱ្យកាន់តែប្រសើរឡើងបន្ថែមទៀត ស្របតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍចលនាអូឡាំពិកកម្ពុជា អាណត្តិទី៩ ឆ្នាំ ២០២៦-២០៣០ ក្នុងការបន្តពង្រឹងឱ្យគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជាក្លាយជាអង្គការកីឡាជាតិ និងចលនាអូឡាំពិកកម្ពុជាមួយ ដែលនៅតែដើរតួនាទីដ៏សំខាន់ និងមិនអាចខ្វះបានក្នុងការអភិវឌ្ឍកីឡាជាតិ និងចលនាអូឡាំពិកកម្ពុជា ដើម្បីលើកកម្ពស់កិត្តិយសកិត្យានុភាពជាតិ។

ថ្ងៃពុធ ៨រោច ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ពស២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦

| **អគ្គលេខាធិការ** | **អគ្គហេរញ្ញិក** | **អ្នកធ្វើរបាយការណ៍** |
|---|---|---|
| **វ៉ាត់ ចំរើន** | **ឧត្តមសេនីយ៍ឯក លី កុសល** | **សួង ស៊ីណារ័ត្ន** |

# គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា

## ផែនការយុទ្ធសាស្ត្រ
## អភិវឌ្ឍចលនាអូឡាំពិកកម្ពុជា

## អាណត្តិទី៩ ប្រចាំឆ្នាំ២០២៦-២០៣០

# បុព្វកថា

ចលនាអូឡាំពិកកម្ពុជាបានត្រូវពង្រឹង និងពង្រីកឡើងវិញ ក្រោយពីគណៈកម្មាធិការអូឡាំពិកអន្តរជាតិ "IOC" ទទួលស្គាល់ជាសមាជិកចលនាអូឡាំពិកជាផ្លូវការដល់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក្រោយបញ្ចប់សង្គ្រាមស៊ីវិលនាឆ្នាំ១៩៩៤។

ក្នុងនាមខ្ញុំជាប្រធានគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អស់រយៈពេលជាង ២០ឆ្នាំកន្លងមក ខ្ញុំមានមោទនភាព និងកោតសរសើរចំពោះការវិវត្តរីកចម្រើនឆាប់រហ័សរបស់ចលនាអូឡាំពិកកម្ពុជា ដែលស្ថិតក្នុងកាលៈទេសៈប្រទេសកម្ពុជាកំពុងរស់នៅក្រោមដំបូលសន្តិភាព និងការអភិវឌ្ឍ។

សមិទ្ធផលដ៏ធំធេង និងអស្ចារ្យនៃចលនាអូឡាំពិកសម្រាប់អាណត្តិទី៨ ប្រចាំឆ្នាំ២០២២-២០២៦ គឺជាជោគជ័យដ៏ត្រចះត្រចង់ក្នុងការធ្វើជាម្ចាស់ផ្ទះរៀបចំការប្រកួតកីឡា SEA Games លើកទី៣២ ឆ្នាំ២០២៣។ ពិតណាស់ SEA Games នៅកម្ពុជាបានបំបែកឯកត្តកម្មជា SEA Games ដែលអស្ចារ្យពុំធ្លាប់មានដូចជា មិនយកថ្លៃស្នាក់នៅ-ហូបចុក ពិធីបដិសណ្ឋារកិច្ចដ៏កក់ក្ដៅ ពិធីបើកកម្រិតអូឡាំពិកជាដើម។ល។

ការរៀបចំផែនការយុទ្ធសាស្ត្រនៃការអភិវឌ្ឍចលនាអូឡាំពិកកម្ពុជាអាណត្តិថ្មី អាណត្តិទី៩ ប្រចាំឆ្នាំ ២០២៦-២០៣០ ផ្អែកតាមធម្មនុញ្ញអូឡាំពិក ស្របជាមួយយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល គឺជារបត់ថ្មីមួយទៀតដែលបានដាក់ចេញនូវមគ្គុទេសក៍ច្បាស់លាស់ក្នុងការចង្អុលបង្ហាញឆ្ពោះទៅរកជោគជ័យនៃចលនាអូឡាំពិកកម្ពុជាបន្ថែមទៀតក្នុងរយៈពេល ៥ឆ្នាំទៅមុខ។

សូមអរគុណដល់ក្រុមការងាររៀតាក់តែងផែនការយុទ្ធសាស្ត្រនេះ និងសូមអរគុណដល់ការគាំទ្រ ជឿជាក់និងជំរុញការអនុវត្តផែនការយុទ្ធសាស្ត្ររបស់គណៈកម្មាធិការប្រតិបត្តិ នៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក៏ដូចសហព័ន្ធកីឡាជាតិជាសមាជិក ព្រមទាំងភាគីពាក់ព័ន្ធទាំងអស់។

សង្ឃឹមថាផែនការយុទ្ធសាស្ត្រនេះនឹងផ្តល់នូវកោលានុវត្តភាពថ្មីសម្រាប់ចលនាអូឡាំពិកកម្ពុជា ក៏ដូចចលនាអូឡាំពិកអន្តរជាតិ។

ថ្ងៃ ខែ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២៦

**បណ្ឌិត ថោង ខុន**

# អារម្ភកថា

ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រអាណត្តិទី៩ សម្រាប់ឆ្នាំ២០២៦-២០៣០ បានខិតខំតាក់តែងរៀបចំវិធីសាស្ត្រសរសេរ និងវិភាគស្ថានភាពច្បាស់លាស់ដែលបានមកពីការសិក្សាស្រាវជ្រាវត្រឹមត្រូវ ដោយគោរពតាមគោលការណ៍វិភាគចំណុចខ្លាំង ចំណុចខ្សោយ បញ្ហាប្រឈម និងដំណោះស្រាយសមស្រប ដើម្បីប្រមូលបានជាតុចូលដែលបានចោទជាបញ្ហាក្នុងការអភិវឌ្ឍ និងដាក់ចេញនូវដំណោះស្រាយដ៏មានប្រសិទ្ធភាពដែលអាចសម្រេចបានលទ្ធផលល្អប្រសើរសម្រាប់ធ្វើឱ្យចលនាអូឡាំពិកកម្ពុជា និងចលនាអូឡាំពិកអន្តរជាតិទទួលបានការអភិវឌ្ឍប្រកបដោយចីរភាព និងបរិយាបន្ន។

ផែនការយុទ្ធសាស្ត្រនេះ គឺជាដំណើរការដឹកនាំគ្រប់គ្រងចាំបាច់ដែលនាំគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា និងភាគីពាក់ព័ន្ធឆ្ពោះទៅរកចក្ខុវិស័យ គោលបំណង បេសកកម្ម និងលទ្ធផលរំពឹងទុកគួរឱ្យទុកចិត្តរបស់ចលនាកីឡាជាតិ និងចលនាអូឡាំពិកកម្ពុជា ឱ្យស្របតាមស្តង់ដាកីឡាអន្តរជាតិ និងមានភាពងាយស្រួលក្នុងការរួមគ្នាគិត រួមគ្នាធ្វើ និងរួមគ្នាទទួលខុសត្រូវ ដោយសហការជាមួយភាគីពាក់ព័ន្ធដើម្បីបង្កើតក្រុមការងារខ្លាំងពូកែមួយពិតប្រាកដ។

សូមថ្លែងអំណរគុណ និងដឹងគុណដល់ភាគីពាក់ព័ន្ធកីឡា សកម្មជន វីរជន ដែលបានលះបង់គ្រប់បែបយ៉ាងដល់ការកសាងចលនាអូឡាំពិកកម្ពុជា។

សូមថ្លែងអំណរគុណដល់ក្រសួងអប់រំ យុវជន និងកីឡា សហព័ន្ធកីឡាជាតិ អង្គភាពកីឡា ក្រសួងស្ថាប័ន និងភាគីពាក់ព័ន្ធកីឡា ដែលផ្តល់នូវសេចក្តីទុកចិត្តដល់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក្នុងការបម្រើ និងអភិវឌ្ឍកីឡាជំនាញកម្រិតខ្ពស់ឆ្ពោះទៅរកភាពជោគជ័យទាំងអស់គ្នា។

**ក្រុមការងាររៀបចំផែនការយុទ្ធសាស្ត្រ**

# ផែនការយុទ្ធសាស្ត្រ អាណត្តិទី៩

**សេចក្តីផ្តើម** :

គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា គឺជាអង្គការកីឡាជាតិមានឯករាជ្យភាព និងស្វ័យភាពពេញលេញក្នុងការដឹកនាំគ្រប់គ្រងចលនាអូឡាំពិកកម្ពុជា និងជាតំណាងឱ្យចលនាអូឡាំពិកអន្តរជាតិប្រចាំអធិបតេយ្យភាពកម្ពុជា។

សហព័ន្ធកីឡាអូឡាំពិក គឺជាសមាជិកស្នូល និងសំខាន់ក្នុងការអភិវឌ្ឍចលនាកីឡាអូឡាំពិក តាមធម្មនុញ្ញអូឡាំពិក និងបទប្បញ្ញត្តិនានារបស់សហព័ន្ធកីឡាអូឡាំពិកអន្តរជាតិ។

រាជរដ្ឋាភិបាល និងស្ថាប័នកីឡាទទួលបន្ទុក គឺជាដៃគូអភិវឌ្ឍដ៏មានឥទ្ធិពល និងប្រសិទ្ធភាពក្នុងការសហការជំរុញការអភិវឌ្ឍចលនាអូឡាំពិក។

គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា អនុវត្តការងារដោយឈរលើធម្មនុញ្ញអូឡាំពិក និងគោរពគោលនយោបាយកីឡាជាតិ គោលការណ៍គន្លឹះ ស្តីពីអប់រំកាយនិងកីឡារបស់រាជរដ្ឋាភិបាល និងក្រសួងអប់រំ យុវជន និងកីឡា ដើម្បីសម្រេចគោលដៅរួមគឺ កសាងអភិវឌ្ឍកីឡាជាតិ និងចលនាអូឡាំពិកកម្ពុជាប្រកបដោយចីរភាព និងបរិយាបន្ន។

ដើម្បីពង្រឹង និងបន្តអភិវឌ្ឍចលនាអូឡាំពិកឈរលើភាពស្របច្បាប់របស់ខ្លួន គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ធ្វើការវិភាគស្ថានភាព ដោយធ្វើបច្ចុប្បន្នកម្ម និងធ្វើបុរេសកម្មឆ្ពោះទៅរកយុទ្ធសាស្ត្រជំរុញ និងកែទម្រង់ថ្មីស៊ីជម្រៅ ឈានទៅធ្វើទំនើបកម្មចលនាអូឡាំពិកកម្ពុជា អនុលោមតាមយុទ្ធសាស្ត្របញ្ចកោណដំណាក់កាលទី១ របស់រាជរដ្ឋាភិបាល។

**ចក្ខុវិស័យ** :

បន្តពង្រឹងឱ្យគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ក្លាយជាអង្គការកីឡាជាតិ និងចលនាអូឡាំពិកកម្ពុជាមួយដែលនៅតែដើរតួនាទីដ៏សំខាន់ និងមិនអាចខ្វះបានក្នុងការអភិវឌ្ឍកីឡាជាតិ និងចលនាអូឡាំពិក។ ជំរុញការអភិវឌ្ឍចលនាអូឡាំពិកឱ្យក្លាយជាចលនាកីឡាជាតិមួយប្រកបដោយគុណភាព សុចរិតភាព និងមានការចូលរួមយ៉ាងទូលំទូលាយ ដើម្បីលើកកម្ពស់គុណភាពនៃការប្រកួតអន្តរជាជាតិ និងលើកកម្ពស់កិត្តិយសកិត្យានុភាពជាតិ។

**បេសកកម្ម** :

ពង្រឹងការអភិវឌ្ឍអត្តពលិក និងមន្ត្រីកីឡា ពង្រឹងសហព័ន្ធកីឡាជាតិ ជំរុញការចូលរួមចលនាកីឡាក្នុងសហគមន៍ និងពង្រឹងសមត្ថភាពដឹកនាំគ្រប់គ្រង ផ្តោតលើគុណតម្លៃចលនាអូឡាំពិក លើការអភិវឌ្ឍមូលធនមនុស្សជំនាញឯកទេសកីឡា និងការធ្វើសុខដុមនីយកម្មការងារកីឡាជាមួយគ្រប់ភាគីពាក់ព័ន្ធ ពិសេសជាមួយសសរស្តម្ភទាំងបី គឺ គណៈកម្មា-ធិការជាតិអូឡាំពិកកម្ពុជា ក្រសួងអប់រំ យុវជន និងកីឡា និងសហព័ន្ធកីឡាជាតិ។

**គោលបំណង** :

ធ្វើឱ្យចលនាអូឡាំពិកកម្ពុជាមានការចូលរួមយ៉ាងទូលំទូលាយពីយុវជន និងមហាជនដើម្បីស្រូបទាញបានការចូលរួមឧបត្ថម្ភគាំទ្រពីគ្រប់ភាគីពាក់ព័ន្ធផ្ទាល់ និងប្រយោល ផ្តល់ទំនុកចិត្តនិងភាពជឿជាក់លើគណៈ-កម្មាធិការជាតិអូឡាំពិកកម្ពុជា ក្នុងការអនុវត្តគោលនយោបាយកីឡាជាតិ និងគោលការណ៍ណែនាំរបស់ចលនាអូឡាំពិកអន្តរជាតិ។ ពិសេសបង្កើតសក្តានុពលភាព ឧត្តមភាពចលនាអូឡាំពិកកម្ពុជានៅលើឆាកជាតិ និងអន្តរជាតិ។

**កម្មវត្ថុ** :

១-ពង្រឹងប្រព័ន្ធគ្រប់គ្រងដឹកនាំប្រកបដោយអភិបាលកិច្ចល្អ តាមស្តង់ដាវាយតម្លៃរបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិ "IOC" លើគ្រប់ភាគីពាក់ព័ន្ធ។

២-ជំរុញការអភិវឌ្ឍមូលធនមនុស្សជំនាញ ពិសេសមន្ត្រីកីឡា គ្រូបង្វឹក និងកីឡាករកម្រិតខ្ពស់ តាមរយៈការចូលរួមសិក្សាស្រាវជ្រាវ និងវគ្គបណ្តុះបណ្តាល និងការហាត់ហ្វឹកហ្វឺនប្រកបដោយគុណភាព ទាំងក្នុង និងក្រៅប្រទេស ជាមួយគ្រូបង្វឹកមានគុណវុឌ្ឍិខ្ពស់ និងបរិយាកាសហ្វឹកហាត់ល្អ។

៣-បង្កើតឧស្សាហកម្មកីឡាឱ្យចេញជាសកម្មភាពជាក់ស្តែង ដើម្បីកៀរគរចំណូល ដូចជា "គម្រោងស្វែងរកមូលនិធិអូឡាំពិក L.A ២០២៨" និងអូឡាំពិក២០៣២ នៅប្រទេសអូស្ត្រាលី។

៤-រៀបចំប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា "ICT" គ្រប់គ្រងព័ត៌មានកីឡាករឆ្នើម កីឡាករជ័យលាភីក្នុង Games និងប្រព័ន្ធ KPI វាយតម្លៃសហព័ន្ធកីឡាជាតិ។

៥-ត្រៀមគ្រប់លក្ខណៈសម្បត្តិមុនព្រឹត្តិការណ៍ប្រកួត "AYG" លើកទី៥ ឆ្នាំ២០៣១ និងជួយរៀបចំ "AYPG" លើកទី៦ ឆ្នាំ២០២៩។

៦-ពង្រឹងការលើកកម្ពស់ទស្សនវិជ្ជាអូឡាំពិកនៅកម្ពុជា និងបន្តជំរុញចលនា "យុវជនម្នាក់ចេះកីឡាមួយប្រភេទយ៉ាងតិចប្រចាំជីវិត" របស់រាជរដ្ឋាភិបាល។

**យុទ្ធសាស្ត្រ** :

១-**អាទិភាពទី១** : សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា សហព័ន្ធកីឡាជាតិ រួមគ្នាពង្រឹងអភិបាលកិច្ចល្អ តាមរយៈការកំណត់របៀបវារៈអភិបាលកិច្ចល្អរៀងរាល់កិច្ចប្រជុំ រៀងរាល់វគ្គបណ្តុះបណ្តាល និងរាល់ការបំប៉នជំនាញវិជ្ជាជីវៈ។ ពិសេសស្តីពីការបណ្តុះបណ្តាលរដ្ឋបាលកីឡាតាមប្រព័ន្ធតម្លាភាព គណនេយ្យភាព សក្តិសិទ្ធិភាព និងភាពស្មោះត្រង់ក្នុងការចូលរួម និងលើកទឹកចិត្តឱ្យមានការទទួលខុសត្រូវខ្ពស់ចំពោះតួនាទី-ភារកិច្ចរបស់ខ្លួន និងបែងចែកអត្ថប្រយោជន៍ដោយសមភាព។

២-**អាទិភាពទី២** : សហការជាមួយក្រសួងអប់រំ យុវជន និងកីឡា សហព័ន្ធកីឡាជាតិ រៀបចំវាយតម្លៃស្តង់ដាគ្រូបង្វឹកកម្រិតខ្ពស់ និងបង្កើនសមត្ថភាពគ្រូបង្វឹក ដោយផ្តល់នូវការបណ្តុះបណ្តាលគុណវុឌ្ឍិវិទ្យាសាស្ត្រកីឡា និងឧត្តមានុវត្តកីឡាកម្រិតខ្ពស់។

៣-**អាទិភាពទី៣** : រៀបចំយុទ្ធសាស្ត្របង្កើតឧស្សាហកម្មកីឡា ដែលគម្រោងដំបូងគឺបង្កើតគម្រោង "Cambodia Olympic Team L.A-2028" កៀរគររកជំនួយឧបត្ថម្ភ និងសប្បុរសជនជួយដល់ការហ្វឹកហាត់ និងចូលរួមប្រកួតជាអន្តរជាតិឱ្យបានច្រើន ក្នុងគោលដៅស្វែងរកកីឡាករពេញសិទ្ធិ (Qualified Athletes) ឱ្យបានច្រើន និងឈានទៅរកជើងឯកអូឡាំពិកដំបូង "First Ever Olympic Champion" ក្នុងកំណត់ត្រាប្រវត្តិសាស្ត្រ នៃចលនាអូឡាំពិកកម្ពុជា។

៤-**អាទិភាពទី៤** : បង្កើតប្រព័ន្ធគ្រប់គ្រង "NOCC-ICT" ក្នុងដំណើរការបរិវត្តកម្មកីឡាឌីជីថល (Digital Sport Integration) ដោយជំហានដំបូងបង្កើត APP រួចក្លាយជា Platform ពេញលេញជាប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាដ៏ល្អមួយ។ ទន្ទឹមនឹងនោះបន្តធ្វើទំនើបកម្ម Website NOCC បច្ចុប្បន្នឱ្យក្លាយជាប្រភពព័ត៌មានសម្បូរបែប មានគុណតម្លៃខ្ពស់សម្រាប់ចលនាអូឡាំពិកជាតិ-អន្តរជាតិ។

៥-**អាទិភាពទី៥** : ដើរតួនាទីស្នូលក្នុងការជំរុញការបង្កើតគណៈកម្មាធិការជាតិរៀបចំការប្រកួត 2031 AYG – 2029 AYPG និងដឹកនាំការអនុវត្តដោយចាប់ផ្តើមដំណើរការរៀបចំត្រៀមគ្រប់លក្ខណៈ

សម្បត្តិឱ្យបានគ្រប់ជ្រុងជ្រោយ ដើម្បីធានាឱ្យដំណើរការរៀបចំប្រកបដោយសមត្ថភាព ប្រសិទ្ធភាព និងអភិបាលកិច្ចល្អ ឈានទៅរកជោគជ័យដ៏ត្រចះត្រចង់ម្តងទៀត។

៦-អាទិភាពទី៦ : ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយអង្គការសាមគ្គីអូឡាំពិក ក្រុមប្រឹក្សាអូឡាំពិកអាស៊ី ក្រសួងអប់រំ យុវជន និងកីឡា ដៃគូអភិវឌ្ឍន៍ និងគ្រឹះស្ថានអប់រំរដ្ឋ និងឯកជន ដើម្បីអប់រំ និងផ្សព្វផ្សាយទស្សនវិជ្ជាអូឡាំពិក និងលើកទឹកចិត្តយុវជនឱ្យចូលរួមក្នុងសកម្មភាពកីឡាឱ្យបានទូលំទូលាយ។

**វិធីសាស្ត្រ**

**សកម្មភាពគន្លឹះ** :

១- បើកវគ្គបណ្តុះបណ្តាលពីរដ្ឋបាលកីឡាដល់សហព័ន្ធកីឡាជាតិ និងអង្គភាពកីឡាពាក់ព័ន្ធស្តីពីស្តង់ដារអភិបាលកិច្ចការងារកីឡា តាមរយៈរូបមន្តនិងគោលការណ៍ណែនាំវាយតម្លៃស្តង់ដាអភិបាលកិច្ចរបស់គណៈកម្មាធិការអូឡាំពិកអន្តរជាតិ (IOC) និងបន្ថែមអំណាចដឹកនាំទន់ (Soft Power) ដូចជាចិត្តសាស្ត្រកីឡា ភាពជាអ្នកដឹកនាំកីឡា និងឥទ្ធិពលនៃវិទ្យាសាស្ត្រកីឡា ឱ៊ីជីថលកីឡា ជាដើម។ ម៉្យាងទៀត គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា កំពុងអភិវឌ្ឍកម្រិតវគ្គរដ្ឋបាលកីឡាឡើងទៅជាកម្រិតរដ្ឋបាលកីឡាជាន់ខ្ពស់ (Advanced Sport Administration) ក្នុងន័យបង្កើតគុណភាពវគ្គឈានទៅបំពាក់សមត្ថភាពដឹកនាំគ្រប់គ្រងអង្គការកីឡាជំនាញឱ្យមានប្រសិទ្ធភាព។

គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា នឹងសហការជាមួយក្រសួងអប់រំ យុវជន និងកីឡា និងសហព័ន្ធកីឡាជាតិ ដើម្បីកំណត់កម្មវិធីវគ្គសិក្សា រៀបចំអ្នកចូលរួមចំគោលដៅ និងរៀបចំគ្រូឧទ្ទេសមានគុណវុឌ្ឍិទាំងខ្មែរ និងបរទេស។

មនុស្សគោលដៅអភិវឌ្ឍ គឺ ទី១ អគ្គលេខាធិការ ទី២ មន្ត្រីរដ្ឋបាល និងទី៣ គ្រូបង្វឹក។

២- អភិវឌ្ឍមូលធនមនុស្សជំនាញ ត្រូវការចាំបាច់នូវការកសាងសមត្ថភាពគ្រូបង្វឹកថ្នាក់ជាតិ ឱ្យឈានដល់កម្រិត License ថ្នាក់អន្តរជាតិ។ កសាងគុណផលកីឡាកម្រិតខ្ពស់ជូនអត្តពលិកជាតិ ផ្តោតលើគុណភាពនៃការហាត់ហ្វឹកហ្វឺនប្រកបដោយវិន័យ ភាពទៀតទាត់ និងការឧបត្ថម្ភគាំទ្រការហាត់ហ្វឹកហ្វឺនគ្រប់គ្រាន់ តាមសេចក្តីត្រូវការចាំបាច់ជាមូលដ្ឋានរបស់កីឡាករ កីឡាការិនីជម្រើសជាតិ។

- តម្រូវការចាំបាច់ជាមូលដ្ឋាន "Basic Needs" របស់កីឡាករ កីឡាការិនី គឺ៖
    - គ្រូបង្វឹកមានសមត្ថភាព បទពិសោធន៍ជំនាញ និងភាពជាអ្នកដឹកនាំត្រឹមត្រូវ ទោះបីជាគ្រូបង្វឹកខ្មែរ ឬ បរទេស ដែលត្រូវតែផ្តល់ជូនកីឡាករកម្រិតខ្ពស់ តាមរយៈផ្តល់វគ្គសិក្សាដោយអនុវត្តផ្ទាល់ជាមួយជំនាញការខាងអភិវឌ្ឍគុណផលកីឡា និងវិទ្យាសាស្ត្រកីឡា ក៏ដូចវេជ្ជសាស្ត្រកីឡា វិធានការការពាររបួសស្នាម វិធីសាស្ត្រស្តារកម្លាំង ស្តារនីតិសម្បទា និងព្យាបាល ព្រមទាំងចិត្តសាស្ត្រកីឡា។
    - ទីលានហ្វឹកហាត់សមស្របតាមស្តង់ដាប្រកួតអន្តរជាតិ ប្រកបដោយបរិយាកាសល្អ បរិស្ថានល្អ អនាម័យល្អ ជាមួយឧបករណ៍កីឡា សម្ភារៈកីឡាស្តង់ដា និងគ្រប់គ្រាន់។
    - មានរបបអាហារល្អ មានកាឡូរីគ្រប់គ្រាន់ និងការគ្រប់គ្រងដំណេកល្អ ការគ្រប់គ្រងពេលវេលាក្នុងកីឡា និងក្រៅពីកីឡាបានត្រឹមត្រូវក្នុងលក្ខខណ្ឌវិន័យតឹងរឹងបំផុត។
    - មានរបបលើកទឹកចិត្តជាប្រចាំដល់កីឡាករក្នុងអាជីព និងក្រោយបញ្ចប់អាជីព។
    - មានការព្យាបាលដោយចលនា ព្យាបាលដោយការស្តារនីតិសម្បទាឡើងវិញ និងការព្យាបាលជំងឺផ្សេងៗជាប្រចាំដោយគ្មានលក្ខខណ្ឌ ជូនដល់កីឡាករជម្រើសជាតិគ្រប់រូបដោយមិនយកកម្រៃ និងមិនរើសអើងគ្រប់រូបភាព។

• កន្លែងសម្រាក និងស្នាក់នៅប្រមូលផ្ដុំកីឡាករជម្រើសជាតិប្រកបដោយផាសុកភាព បរិយាកាសល្អ អនាម័យល្អ និងសម្ភារៈបរិក្ខារដំណេកគុណភាពល្អ។

- វគ្គបណ្ដុះបណ្ដាលសំដៅលើការអនុវត្តផ្ទាល់ ដោយមានការណែនាំពីអ្នកជំនាញជាតិ-អន្តរជាតិ ស្វែងរកដៃគូអន្តរជាតិជួយផ្ដល់វគ្គខ្លី ខ្លឹម និងលទ្ធផលល្អប្រសើរជាក់ស្ដែង។
- យកមនុស្សគោលដៅ គឺ គ្រូបង្វឹកបង្គោល គ្រូជំនួយ អនុរក្ស និងក្រុមគ្រូពេទ្យពាក់ព័ន្ធមក បណ្ដុះបណ្ដាលមុន។ កីឡាករត្រូវអនុវត្តជាក់ស្ដែងជាមួយការកែលម្អភ្លាមៗ។

❖ វិទ្យាសាស្ត្រកីឡា ជាមេរៀន និងវិធីសាស្ត្រហាត់ហ្វឹកហ្វឺនកីឡាមិនអាចខ្វះបានក្នុងសម័យកីឡាទំនើប និងបញ្ញាសិប្បនិម្មិត "AI"។

៣- ឧស្សាហកម្មកីឡា : ស្វែងរកការដាក់ទុនវិនិយោគពីវិស័យឯកជនក្នុងការផលិតផលិតផលកីឡា ដែលអាចលក់ដូរដាក់ម្រែបាន និងពង្រឹងប្រភពចំណូលតាមរយៈសកម្មភាពកីឡា និងព្រឹត្តិការណ៍កីឡា ដោយរៀបចំទីផ្សារកីឡា និងការផ្សព្វផ្សាយផលិតផលកីឡាតាមរយៈការបង្កើតមាតិកាសង្គម និង បេះប្រើប្រាស់ប្រព័ន្ធបណ្ដាញសង្គមជាប្រយោជន៍នៃការស្វែងរកចំណូល។

• ការរៀបចំកៀរគរចំណូលតាមរយៈកម្មវិធីពិសេសៗនានាដូចជា "Cambodia Olympic Team" ក្នុងគោលបំណងឱ្យកីឡាករកម្ពុជាជាប់ពេញសិទ្ធិ "Qualified Athlete" ឱ្យបានច្រើននៅការប្រកួតកីឡាអូឡាំពិក និងជំរុញឱ្យប្រជែងរកមេដាយដំបូងក្នុងការប្រកួតអូឡាំពិកនាពេលអនាគត។ រីឯវិធីសាស្ត្ររកចំណូលធ្វើតាមរយៈ "Sponsors" និង "វិភាគទានបរិច្ចាកសប្បុរសរបស់មហាជនទូទៅ"។ សកម្មភាពនៃការចាប់ផ្ដើមយុទ្ធនាការគឺ ចាប់ពីពេលនេះត ទៅតាមរយៈការផ្សព្វផ្សាយទាក់ទាញការចូលរួមឧបត្ថម្ភគាំទ្រ ដោយប្រើប្រាស់ប្រព័ន្ធ "APP-NOCC" និងការជួយពីធនាគារក្នុងស្រុក "ABA" និងសភាពាណិជ្ជកម្មអាមេរិកប្រចាំកម្ពុជាផងដែរ។

៤- Website NOCC "olympiccambodia.com" បាននឹងកំពុងអភិវឌ្ឍគុណភាព និងបញ្ចូលធាតុផ្សំបច្ចេកទេសវិទ្យាថ្មីៗ ថែមទៀត។ ជាគោលដៅគឺត្រូវអភិវឌ្ឍ Website-NOCC ឱ្យក្លាយជាប្រព័ន្ធគ្រប់គ្រងទិន្នន័យ ស្ថិតិ និងព័ត៌មានផ្លូវការរបស់ចលនាអូឡាំពិកកម្ពុជា និងជាមជ្ឈមណ្ឌលប្រកបង្គួចតែមួយគត់ក្នុងការសិក្សាស្រាវជ្រាវស្វែងរកព័ត៌មានគ្រប់ជ្រុងជ្រោយ និងផ្លូវការរបស់បញ្ញាសិប្បនិម្មិត "AI" ដែលអាចជួយដល់ការគ្រប់គ្រង និងជួយអភិវឌ្ឍបច្ចេកទេសកីឡា តាមរយៈកិច្ចសហការជាមួយអ្នកជំនាញ "AI" ។

៥- កំណត់កម្មវិធី និងប្រតិទិនការងារត្រៀមរៀបចំការប្រកួតកីឡាជនពិការយុវជនអាស៊ី "AYPG" លើកទី៦ ឆ្នាំ២០២៩ និងការប្រកួតកីឡាយុវជនអាស៊ី "AYG" លើកទី៥ ឆ្នាំ២០៣១ ដោយជំរុញការបង្កើតសមាសភាពថ្នាក់ដឹកនាំគណៈកម្មាធិការជាតិរៀបចំ ឱ្យរួចរាល់ក្នុងឆមាសទី១ ឆ្នាំ២០២៦ ក្រោយពីទទួលបានអនុក្រឹត្យស្ដីពីការបង្កើតគណៈកម្មាធិការជាតិរួចមក។

- ផែនការមេ និងផែនការសកម្មភាពត្រូវរៀបចំ និងសម្រេច ក្រោយពីបង្កើតបានសមាសភាពថ្នាក់ដឹកនាំគណៈកម្មាធិការជាតិរៀបចំប្រកួតរួច។
- ដំណើរការគណៈកម្មាធិការជាតិរៀបចំ អាស្រ័យលើការសម្រេចរបស់ប្រធានគណៈកម្មាធិការជាតិរៀបចំ។

៦- ពង្រឹង និងពង្រីកការអនុវត្តកម្មវិធីអប់រំគុណតម្លៃអូឡាំពិកប្រចាំឆ្នាំរបស់ NOCC រួមមាន ទិវាអូឡាំពិក កីឡាសម្រាប់ទាំងអស់គ្នា កីឡាដើម្បីបរិស្ថាន កីឡាដើម្បីទេសចរណ៍ កីឡាដើម្បីសន្តិភាព កម្មវិធីសមភាព និងការលើកកម្ពស់ស្ត្រីក្នុងវិស័យកីឡា ព្រមទាំងជំរុញយុទ្ធនាការអប់រំសង្គមឆ្ពោះទៅការធ្វើជាម្ចាស់ផ្ទះការប្រកួតកីឡាយុវជនអាស៊ី ប៉ាប៉ាហ្គេម ឆ្នាំ២០២៩ និងការប្រកួតកីឡាយុវជនអាស៊ី ឆ្នាំ២០៣១ នៅតាមគ្រឹះស្ថានសិក្សារដ្ឋ និងពង្រឹងកិច្ចសហប្រតិបត្តិការជាមួយគ្រឹះស្ថានសិក្សា អង្គការដៃគូអភិវឌ្ឍន៍ និងវិស័យឯកជន ដើម្បីពង្រីកការផ្សព្វផ្សាយទស្សនវិជ្ជា និងគុណតម្លៃអូឡាំពិកឱ្យបានទូលំទូលាយនៅទូទាំងប្រទេស។

**ធនធាន**:

- ធនធានចរន្តរបស់គណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា បានមកពីការគាំទ្រហិរញ្ញវត្ថុក្នុងដំណើរការរដ្ឋបាល និងសកម្មភាពអប់រំអូឡាំពិក វគ្គបណ្តុះបណ្តាលជំនាញគ្រូបង្វឹក រដ្ឋបាលកីឡាពីគណៈកម្មាធិការអូឡាំពិកអន្តរជាតិ "IOC" និងក្រុមប្រឹក្សាអូឡាំពិកអាស៊ី "OCA" តាមរយៈអង្គការសាមគ្គីអូឡាំពិក "OS"។
- បន្តថែរក្សាជំនួយឧបត្ថម្ភគាំទ្រពីរាជរដ្ឋាភិបាល តាមរយៈក្រសួងអប់រំ យុវជន និងកីឡា លើថាមពលអគ្គិសនី ទឹក និងបេសកកម្មចូលរួមប្រកួតពហុកីឡាជា "Games"។ល។
- បន្តពង្រឹងការរៀបចំព្រឹត្តិការណ៍កីឡាមហាជន និងការប្រកួតផ្សេងៗកម្រិតជាតិ និងអន្តរជាតិរៀបចំក្នុងប្រទេស ដោយស្វែងរកការជួយឧបត្ថម្ភគាំទ្រពីវិស័យឯកជន។

ធនធានបច្ចុប្បន្ននៅមិនទាន់ឆ្លើយតប និងមានសមភាពធៀបជាមួយទំហំចំណាយបានទេ ព្រោះការធ្វើទំនើបកម្ម និងបង្កើនគុណផលកីឡាកម្រិតខ្ពស់តាមស្តង់ដាកីឡាអន្តរជាតិមានតម្លៃថ្លៃ និងកើនតម្លៃចំណាយជារៀងរាល់ថ្ងៃ។

ដូចនេះការដាក់ចេញនូវគោលការណ៍កៀរគរចំណូល តាមរយៈការធ្វើទីផ្សារកីឡា ផ្សព្វផ្សាយកីឡា និងឧស្សាហកម្មកីឡា គឺជាការចាំបាច់ក្នុងបរិយាកាសសេដ្ឋកិច្ចធ្លាក់ចុះ និងជួបវិបត្តិបច្ចុប្បន្ន។

**សូចនាករ** :

ដើម្បីវាស់វែងលទ្ធផលជាក់ស្តែងត្រូវបង្កើតយន្តការតាមដាន ត្រួតពិនិត្យ វាយតម្លៃ ទាំងបរិមាណវិស័យ និងទាំងគុណវិស័យនៃចលនាអូឡាំពិកកម្ពុជា។ ក្នុងនោះគណៈកម្មាធិការប្រតិបត្តិ នៃគណៈ-កម្មាធិការជាតិអូឡាំពិកកម្ពុជា មានភារកិច្ចតាមដាន ត្រួតពិនិត្យ វាយតម្លៃ ដោយគោរពរបបប្រជុំទៀងទាត់រៀងរាល់បីខែម្តង និងបើកកិច្ចប្រជុំពិសេសពេលមានការចាំបាច់។ អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិអូឡាំពិកកម្ពុជា ត្រូវអនុវត្តយុទ្ធសាស្ត្រនេះឱ្យមានប្រសិទ្ធភាពខ្ពស់ និងត្រូវវាយការណ៍វឌ្ឍនភាពជាប្រចាំ និងស្នើសុំយោបល់ថ្នាក់ដឹកនាំពេលជួបបញ្ហារាំងស្ទះ។ ដើម្បីកំណត់លទ្ធផល និងសមិទ្ធផលនៃសូចនាករផែនការយុទ្ធសាស្ត្រនេះបានទទួលជោគជ័យកម្រិតណា ឬ បរាជ័យចំណុចណា គឺមានតែមហាសន្និបាតប្រចាំឆ្នាំ បូកសរុបការងារ និងលើកទិសដៅបន្តប្រចាំឆ្នាំតែមួយគត់ដែលមានសមត្ថកិច្ច និងអំណាចផ្តាច់មុខក្នុងការវាយតម្លៃសូចនាករសមិទ្ធកម្មនៃផែនការយុទ្ធសាស្ត្រនេះបាន។

ផែនការយុទ្ធសាស្ត្រនេះជោគជ័យតាមសូចនាករចង់បាន អាស្រ័យលើស្មារតីកីឡា ស្មារតីសាមគ្គីភាព ឯកភាពផ្ទៃក្នុងនៃមហាគ្រួសារកីឡា និងភាគីពាក់ព័ន្ធដោយឆន្ទៈរួមគ្នាគិត រួមគ្នាធ្វើ និងរួមគ្នាទទួលខុសត្រូវ។ ប៉ុន្តែផែនការយុទ្ធសាស្ត្រនេះនឹងត្រូវបត់បែន ទន់ភ្លន់ និងសម្របសម្រួលតាមបរិយាកាស និងហេតុការណ៍កើតឡើងជាក់ស្តែង។